**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ប្រតិភូកម្មអំណាច និងប្រតិភូកម្មហត្ថលេខា

## (ផ្តោតលើជ្រុងទស្សនៈទ្រឹស្តី និងការអនុវត្តជាក់ស្តែង)

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦

រៀបរៀងដោយ

និស្សិតឈ្មោះ **នុត វិច្ឆិកា**

សាស្ត្រាចារ្យណែនាំ

លោក **ឡើក ពិដោរ**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ០៩ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១២

ឆ្នាំសរសេរសារណា ២០១៦

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **នុត វិច្ឆិកា** ជានិស្សិតអាហារូបករណ៍ ថ្នាក់បរិញ្ញាប័ត្ររដ្ឋបាលសាធារណៈ ឆ្នាំទី៤ ជំនាន់ទី០៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចាប់ពីឆ្នាំសិក្សា ២០១២-២០១៦៖

សូមលំឱនកាយសម្តែងនូវកត្តាញ្ញុតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

លោកឪពុក **នុត សុភាព** ព្រមទាំងអ្នកម្តាយ **ខាន់ សុផាន់** ដែលបានផ្តល់កំណើត និងខិតខំតស៊ូចិញ្ចឹមបីបាច់ ថែរក្សា ផ្តល់ភាពកក់ក្តៅ អប់រំ ទូន្មាន ប្រៀនប្រដៅ ជ្រោមជ្រែង ផ្គត់ផ្គង់ទាំងស្មារតី សម្ភារៈ និង ថវិកា ព្រមទាំងលះបង់គ្រប់បែបយ៉ាង ទាំងពេលវេលានិងកម្លាំងកាយចិត្ត ដើម្បីរកប្រាក់កម្រៃមកឧបត្ថម្ភខ្ញុំបាទឲ្យបានមានឱកាសសិក្សារៀនសូត្រ តាំងពីថ្នាក់បឋមសិក្សា ដល់បញ្ចប់ថ្នាក់វិទ្យាល័យ ថែមទាំងឈានដល់ថ្នាក់ឧត្តមសិក្សាបន្តទៀត។ នេះជាគុណូបការៈដ៏ធំធេងបំផុត ដែលលោកអ្នកមានគុណទាំងពីរបានផ្តល់ឲ្យសម្រាប់ឲ្យកូនមានពន្លឺក្នុងការកសាងអនាគត និងក្លាយជាបុគ្គលម្នាក់ដែលមានប្រយោជន៍ដល់គ្រួសារ និងសង្គមជាតិ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង** ថ្នាក់ដឹកនាំ និងសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការដឹកនាំ គ្រប់គ្រង ជួយជ្រោមជ្រែង និងបង្ហាត់បង្រៀនយើងខ្ញុំឲ្យមានការយល់ដឹងច្រើន មិនត្រឹមតែជំនាញផ្នែកនីតិសាស្ត្រ និងរដ្ឋបាលសាធារណៈប៉ុណ្ណោះទេ ថែមទាំងចេះផ្តល់ពុទ្ធិអំពីស្ថានភាពនានាដែលកើតមានក្នុងសង្គមទៀត។

ខ្ញុំបាទសូមថ្លែងអំណរគុណជាពិសេសចំពោះ លោកសាស្ត្រាចារ្យ **ឡើក ពិដោរ** លោកជាសាស្ត្រាចារ្យដែលមានបទពិសោធន៍ និងចំណេះជំនាញយ៉ាងពិតប្រាកដ ផ្នែកនីតិសាធារណៈ ជាពិសេសនីតិរដ្ឋបាល តាមរយៈការចងក្រងជាសៀវភៅដ៏មានតម្លៃ ដែលត្រូវបានមជ្ឈដ្ឋានទូទៅទទួលស្គាល់ច្រើន។ លោកសាស្ត្រាចារ្យ បានចំណាយអស់ពីកម្លាំងកាយចិត្ត និងពេលវេលាដ៏មានតម្លៃរបស់លោកដើម្បីយកមកជួយពន្យល់ណែនាំ និងតម្រង់ផ្លូវយ៉ាងមានប្រសិទ្ធិភាព ទើបខ្ញុំបាទអាចសម្រេចសមិទ្ធិផលសារណាមួយនេះឡើង។

ខ្ញុំបាទសូមអរគុណផងដែរ ចំពោះមិត្តភក្តិទាំងអស់ដែលតែងតែជួយផ្តល់នូវកម្លាំងចិត្ត និងផ្តល់នូវឯកសារនានា ដែលពាក់ព័ន្ធនឹងប្រធានបទ រហូតដល់ខ្ញុំបាទអាចបញ្ចប់សារណាបញ្ចប់ការសិក្សានេះ។

ជាចុងក្រោយខ្ញុំបាទសូមជូនពរលោកឪពុក អ្នកម្ដាយ ឯកឧត្ដមសាកលវិទ្យាធិការ លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យគ្រប់រូបនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ព្រមទាំងមិត្តភក្តិ ប្រកបដោយសេចក្តីសុខ ចំរើនថ្កាន ទទួលបានជោគជ័យលើគ្រប់ភារកិច្ច និងមានសុខភាពល្អគ្រប់ពេលវេលា។

# អារម្ភកថា

បន្ទាប់ពីបានសិក្សា និងស្រាវជ្រាវលើផ្នែករដ្ឋបាលសាធារណៈអស់រយៈពេលជិត៤ឆ្នាំកន្លងមក ព្រមទាំងមានការពន្យល់ណែនាំពីសំណាក់លោកសាស្ត្រាចារ្យនានារួចមក ខ្ញុំបាទបានធ្វើការជ្រើសរើសយកប្រធានបទមួយឡើងដើម្បីធ្វើការសិក្សា ស្រាវជ្រាវ ដើម្បីធ្វើជាសារណាបញ្ចប់ការសិក្សារបស់ខ្ញុំបាទ។

កម្រងឯកសារដែល ទ្រង់ឯកឧត្តម លោកជំទាវ លោក លោកស្រី និស្សិត និងអ្នកសិក្សាស្រាវជ្រាវកំពុងតែអាននេះមានចំណងជើងថា " **ប្រតិភូកម្មអំណាច និងប្រតិភូកម្មហត្ថលេខា ( ផ្តោតលើជ្រុងទស្សនៈទ្រឹស្តី និងការអនុវត្តជាក់ស្តែង)** " ដែលសារណានេះ រៀបចំឡើងក្នុងឱកាសនៃការបញ្ចប់ការសិក្សាថ្នាក់រដ្ឋបាលសាធារណៈរបស់ខ្ញុំបាទ។ សារណាមួយនេះ គឺជាកិច្ចការដ៏មានតម្លៃចំពោះរូបខ្ញុំបាទផ្ទាល់ ក្នុងការបង្ហាញនូវសមត្ថភាព និងចំណេះដឹងដែលបានសិក្សារៀនសូត្រអស់រយៈពេល៤ឆ្នាំកន្លងមកនេះ ដើម្បីធ្វើការចែករំលែកការស្រាវជ្រាវ និងចំណេះដឹងទាំងនោះ ទៅកាន់អ្នកសិក្សាស្រាវជ្រាវក្រោយៗទៀត។

ប្រធានបទមួយនេះផ្តោតសំខាន់ទៅលើការធ្វើប្រតិភូកម្ម ដែលមានតាំងពីថ្នាក់ជាតិ រហូតដល់ថ្នាក់ក្រោមជាតិ ។ ក្នុងនោះដែរយើងបានលើកយកពីសញ្ញាណនានានៃការធ្វើប្រតិភូកម្ម និងការអនុវត្តជាក់ស្តែងក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ។

ជាទីបញ្ចប់ខ្ញុំបាទ សង្ឃឹមថា សារណានេះ នឹងអាចក្លាយជាឯកសារជំនួយស្មារតី និងបន្ថែមការយល់ដឹងទៅលើការសិក្សាផ្នែករដ្ឋបាលបានមួយកម្រិតទៀតដល់មិត្តនិស្សិត និងអ្នកស្រាវជ្រាវទាំងអស់គ្នា ប៉ុន្តែដោយសារតែបទពិសោធន៍ ចំណេះដឹង និងឯកសារសម្រាប់ប្រើប្រាស់ក្នុងការស្រាវជ្រាវរបស់ខ្ញុំបាទនៅមានកម្រិតនៅឡើយ ហេតុដូចនេះ សារណាមួយនេះពិតជានៅមានចន្លោះខ្វះខាតជាច្រើនទៀតជាពុំខានឡើយ ខ្ញុំបាទសូមអភ័យទោសទុកជាមុននូវរាល់កំហុសឆ្គងដែលបានកើតឡើងដោយប្រការណាមួយដោយអចេតនា។ ខ្ញុំបាទរីករាយទទួលយកដោយក្តីសោមនស្ស នូវរាល់ការរិះគន់ដើម្បីស្ថាបនារបស់មិត្តអ្នកអានទាំងអស់ ដើម្បីជួយធ្វើការកែតម្រូវសារណាមួយនេះ ឲ្យកាន់តែមានសុក្រឹត្យភាពបន្ថែមទៀត។

# មាតិកា

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១
## ទ្រឹស្តីទូទៅ

**ផ្នែកទី១៖លក្ខខណ្ឌនៃប្រតិភូកម្មអំណាច និងប្រតិភូកម្មហត្ថលេខា** ........ ៣

កថាខណ្ឌ១៖ លក្ខខណ្ឌរួម ........ ៣

ក- ប្រតិភូកម្មត្រូវមានអត្ថបទច្បែង ........ ៣

ខ- ប្រតិភូកម្មត្រូវសរសេរជាលាយលក្ខណ៍អក្សរ ........ ៤

គ- ប្រតិភូកម្មត្រូវធ្វើឡើងដោយផ្នែក ........ ៥

ឃ- ប្រតិភូកម្មត្រូវធ្វើឡើងដោយស្តែងឡើងច្បាស់លាស់ និងជាក់លាក់ ........ ៥

កថាខណ្ឌ២៖ លក្ខខណ្ឌផ្ទាល់សម្រាប់ប្រភេទនីមួយៗ ........ ៦

ក- ប្រតិភូកម្មអំណាច ........ ៦

ខ- ប្រតិភូកម្មហត្ថលេខា ........ ៨

កថាខណ្ឌ៣៖ ប្រៀបធៀបប្រតិភូកម្មអំណាច និងប្រតិភូកម្មហត្ថលេខា ........ ១១

**ផ្នែកទី២៖ អានុភាពគតិយុត្តនៃប្រតិភូកម្ម** ........ ១៣

កថាខណ្ឌ១៖ អានុភាពគតិយុត្តនៃប្រតិភូកម្ម ចំពោះអាជ្ញាធរដែលធ្វើប្រតិភូកម្ម ........ ១៣

ក- នៅក្នុងប្រតិភូកម្មអំណាច ........ ១៣

ខ- នៅក្នុងប្រតិភូកម្មហត្ថលេខា ........ ១៣

កថាខណ្ឌ២៖ អានុភាពគតិយុត្តនៃប្រតិភូកម្មចំពោះអាជ្ញាធរដែលទទួលប្រតិភូកម្ម ........ ១៤

ក- ចំពោះប្រតិភូកម្មអំណាច ........ ១៤

ខ- ចំពោះប្រតិភូកម្មហត្ថលេខា ........ ១៥

កថាខណ្ឌ៣៖ អានុភាពគតិយុត្តចំពោះប្រជាពលរដ្ឋ ........ ១៥

ក- ចំពោះប្រតិភូកម្មអំណាច ............................................................................................... ១៦

ខ- ចំពោះប្រតិភូកម្មហត្ថលេខា ........................................................................................ ១៦

កថាខណ្ឌ៤៖ ការបញ្ចប់ប្រតិភូកម្ម ........................................................................................ ១៦

ក- ការបញ្ចប់ប្រតិភូកម្មអំណាច ........................................................................................ ១៧

១-ការបញ្ចប់ប្រតិភូកម្មដោយមានលិខិតដកមកវិញ .................................................. ១៧

២- ការបញ្ចប់ប្រតិភូកម្មដោយការងារបានអនុវត្តរួច ឬការបញ្ចប់ដោយស្វ័យប្រវត្តិ ..... ១៧

ខ- ការបញ្ចប់ប្រតិភូកម្មហត្ថលេខា .................................................................................. ១៨

១- ការបញ្ចប់ប្រតិភូកម្មហត្ថលេខាដោយការងារត្រូវបញ្ចប់ ........................................ ១៨

២- ការបញ្ចប់ប្រតិភូកម្មហត្ថលេខាដោយការផ្លាស់ប្តូរបុគ្គលដែលធ្វើប្រតិភូកម្ម ឬបុគ្គលដែលទទួលប្រតិភូកម្ម ......................................................................................................... ១៨

## ជំពូកទី ២

## ការអនុវត្តជាក់ស្តែងនៅកម្ពុជា

**ផ្នែកទី១៖ ប្រតិភូកម្មថ្នាក់ជាតិ** ........................................................................................ ២០

កថាខណ្ឌ១៖ ព្រះមហាក្សត្រ ................................................................................................. ២០

កថាខណ្ឌ២៖ នាយករដ្ឋមន្ត្រី ................................................................................................ ២២

កថាខណ្ឌ៣៖ រដ្ឋមន្ត្រី .......................................................................................................... ២៣

**ផ្នែកទី២៖ ប្រតិភូកម្មថ្នាក់ក្រោមជាតិ** ............................................................................... ២៧

កថាខណ្ឌ១៖ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ...................................................... ២៧

ក- អភិបាលនៃគណៈអភិបាលរាជធានី ................................................................................. ២៧

១- ប្រតិភូកម្មនៅក្នុងរបៀបរបបការងាររបស់គណៈអភិបាលរាជធានី ........................ ២៧

២- ប្រតិភូកម្មនៅក្នុងទំនាក់ទំនងរវាងរដ្ឋបាលរាជធានីជាមួយរដ្ឋបាលខណ្ឌ................ ២៩

៣- ប្រតិភូកម្មនៅក្នុងទំនាក់ទំនងរវាងរដ្ឋបាលរាជធានីជាមួយរដ្ឋបាលសង្កាត់ ............ ២៩

ខ- អភិបាលនៃគណៈអភិបាលខេត្ត ..................................................................................... ៣០

១- ប្រតិភូកម្មនៅក្នុងរបៀបរបបការងាររបស់គណៈអភិបាលខេត្ត ........ ៣០
២- ប្រតិភូកម្មនៅក្នុងទំនាក់ទំនងរវាងរដ្ឋបាលខេត្ត ជាមួយរដ្ឋបាលក្រុង ស្រុក ឃុំ និង សង្កាត់ ........ ៣១
កថាខណ្ឌ២៖ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ........ ៣២
ក- អភិបាលនៃគណៈអភិបាលក្រុង ........ ៣២
១- ប្រតិភូកម្មនៅក្នុងរបៀបរបបការងាររបស់គណៈអភិបាលក្រុង ........ ៣២
២- ប្រតិភូកម្មក្នុងទំនាក់ទំនងរវាងរដ្ឋបាលក្រុងជាមួយរដ្ឋបាលឃុំ សង្កាត់ ........ ៣៣
ខ- គណៈអភិបាលនៃអភិបាលស្រុក ........ ៣៤
១- ប្រតិភូកម្មនៅក្នុងរបៀបរបបការងាររបស់គណៈអភិបាលស្រុក ........ ៣៥
២- ប្រតិភូកម្មក្នុងទំនាក់ទំនងរវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលឃុំ ........ ៣៥
គ- អភិបាលនៃគណៈអភិបាលខណ្ឌ ........ ៣៦
១- ប្រតិភូកម្មនៅក្នុងរបៀបរបបការងាររបស់គណៈអភិបាលខណ្ឌ ........ ៣៧
២- ប្រតិភូកម្មក្នុងទំនាក់ទំនងរវាងរដ្ឋបាលខណ្ឌជាមួយរដ្ឋបាលសង្កាត់ ........ ៣៨
កថាខណ្ឌ៣៖ រដ្ឋបាលឃុំ សង្កាត់ ........ ៣៨
សន្និដ្ឋាន ........ ៤១
អនុសាសន៍ ........ ៤២
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

នូវរាល់លិខិតរដ្ឋបាល ចោទឡើងនូវបញ្ញត្តិទទួលប្រតិភូកម្ម ដែលដាក់បង្ខំ គតិយជនត្រូវតែគោរព លិខិតនោះត្រូវធ្វើចេញពីអាជ្ញាធរមួយដែលមានសមត្ថភាពតាមផ្លូវច្បាប់ដើម្បីធ្វើវា។ សមត្ថភាពនេះត្រូវវាយតម្លៃថាជាសមត្ថកិច្ច ( នៅទីនេះ គឺជាសមត្ថកិច្ចគតិយុត្ត ដែលមិនត្រូវច្រលំជាមួយសមត្ថកិច្ចបច្ចេកទេសទេ ទោះបីជាសមត្ថកិច្ចទាំងពីរគួរតែនៅត្រូតស៊ីគ្នា ហើយត្រូវកាន់កាប់ដោយអាជ្ញាធរតែមួយក៏ដោយ )។ សមត្ថកិច្ចគតិយុត្ត មិនត្រូវបានសន្មតទេក្នុងករណីណាដែលវាស្ថិតនៅក្នុងសណ្តាប់ធ្នាប់សាធារណៈ ពីព្រោះវាមិនអាចត្រូវបានកែសម្រួលបានទោះបីជាភាគីផ្សេងៗយល់ព្រមដើម្បីកែកុនវាខ្លះក៏ដោយ ហើយអាជ្ញាធររដ្ឋបាលមិនអាចបំពានសមត្ថកិច្ចរបស់អាជ្ញាធរមួយទៀតបានឡើយ ទោះជាអាជ្ញាធរនៅក្រោមបង្គាប់ក៏ដោយ[១]។

អ្វីទៅជាប្រតិភូកម្ម?

តាមវចនានុក្រម La Toupie ប្រតិភូកម្ម មានន័យបួនយ៉ាង៖

ន័យទី១ ប្រតិភូកម្មគឺជាអំពើនៃការផ្ទេរ ពោលគឺៈ

– ដាក់បន្ទុកឲ្យបរវេន្តបុគ្គល ឬនីតិបុគ្គលនូវបេសកកម្មមួយ មុខងារមួយ ជាមួយនឹងអំណាចធ្វើសកម្មភាព។

– ផ្ទេរអំណាចទៅឲ្យអ្នកណាម្នាក់ ឧទាហរណ៍ ប្រតិភូកម្មអំណាច ប្រតិភូកម្មហត្ថលេខា ។

ប្រតិភូកម្មអំណាចគឺជាលិខិតគតិយុត្តមួយដែលតាមនេះ អាជ្ញាធរមួយ (អាជ្ញាធរធ្វើប្រតិភូកម្ម) ដកខ្លួនចេញពីអំណាចរបស់ខ្លួនមួយផ្នែក ហើយផ្ទេរអំណាចទាំងនោះទៅឲ្យអាជ្ញាធរក្រោមបង្គាប់របស់ខ្លួន(អាជ្ញាធរទទួលប្រតិភូកម្ម)។ ដូច្នេះ អាជ្ញាធរទទួលប្រតិភូកម្មធានាកាតព្វកិច្ច និងការទទួលខុសត្រូវទាក់ទងទៅនឹងអំណាចដែលត្រូវបានផ្ទេរមកឲ្យខ្លួន។ ក្នុងករណីខកខាន មិនបានបំពេញកាតព្វកិច្ច ដែលត្រូវដាក់ទណ្ឌកម្មព្រហ្មទណ្ឌនោះ អាជ្ញាធរទទួលប្រតិភូកម្មទទួលខុសត្រូវជំនួសអាជ្ញាធរធ្វើប្រតិភូកម្ម។

ក្នុងច្បាប់បារាំង ប្រតិភូកម្មនៃសេវាសាធារណៈ គឺបណ្តាកិច្ចសន្យាទាំងអស់ដែលតាមនេះ អាជ្ញាធរទទួលប្រតិភូកម្មសេវាសាធារណៈ ឬឯកជន ត្រូវបានគេប្រគល់មកឲ្យខ្លួន នូវការ

[១] CCA 27 décembre 1957, Sieur NDJOCK Paul c/Etat du Cameroun

គ្រប់គ្រងនៃសេវាសាធារណៈមួយដោយនីតិបុគ្គលនៃនីតិសាធារណៈ (សមូហភាពដែនដី) ដែលទទួលខុសត្រូវពីរឿងនេះ ប្រសិនបើសមូហភាពដែនដីបានជ្រើសយកការគ្រប់គ្រងសេវាសាធារណៈដោយផ្ទាល់ គេនិយាយពីការគ្រប់គ្រងជារដ្ឋាករ។

ខាងនីតិរដ្ឋធម្មនុញ្ញវិញ ប្រតិភូកម្មច្បាប់មួយគឺជាអំណាចផ្តល់ដោយសភាទៅឲ្យរដ្ឋាភិបាលក្នុងការចេញវិធានការដោយក្រឹត្យ-ច្បាប់ដែលតាមធម្មតាស្ថិតនៅក្រោមសមត្ថកិច្ចរបស់សភា។

ន័យទី២ ប្រតិភូកម្ម គឺជាប្រតិបត្តិការមួយដែលតាមនេះ បុគ្គលម្នាក់ (អ្នកធ្វើប្រតិភូកម្ម) បង្គាប់ឲ្យបុគ្គលម្នាក់ទៀត (ប្រតិភូ) ក្នុងការធ្វើ ឬសន្យាបំពេញតាវកាលិកទៅឲ្យអ្នកទីបី ( អ្នកទទួលប្រតិភូកម្ម)។ ឧទាហរណ៍ ការសងបំណុល ដែលអ្នកធ្វើប្រតិភូកម្មមានចំពោះអ្នកទទួលប្រតិភូកម្ម។

ន័យទី៣ ប្រតិភូកម្មគឺជា ក្រុមបុគ្គល ដែលទទួលអាណត្តិ ដោយក្រុមមួយទៀតសំខាន់ជាង ឬដោយអាជ្ញាធរដែលមានអំណាចខាងស្មារតី ដើម្បីតំណាងឲ្យបុគ្គលនោះនៅក្នុងកាលៈទេសៈពិសេស ឧទាហរណ៍ ប្រតិភូកម្មសហជីព( មានន័យដូចការតំណាងដែរ)។

ន័យទី៤ គឺជាបេសកកម្មមួយ ឬជាការតំណាងការទូត ។

ប៉ុន្តែភាពមធ្យ័តដែលគេសង្កេត នៅក្នុងរូបមន្តនៃគោលការណ៍នេះ ជួនកាល វាលើកឡើងចំពីតថភាពតែម្តង។ ភាពចាំបាច់នៃជីវភាពប្រចាំថ្ងៃ ជាពិសេសការគោរពនិរន្តរភាពនៃសេវាសាធារណៈបាននាំឲ្យរកឃើញនូវការបន្ធូរវិធានដ៏តឹងរ៉ឹងនេះ ដែលក្នុងនោះរួមមាន ប្រតិភូកម្មអំណាច និងប្រតិភូកម្មហត្ថលេខា ។ បច្ចេកទេសទាំង២នេះ សំដៅសម្រាលភារកិច្ចរបស់អាជ្ញាធរមួយ ហើយមិនមានន័យដូចគ្នានោះទេ។

ទោះបីជាយ៉ាងនេះក្តី ក្នុងការអនុវត្តជាក់ស្តែង មិនដូចទៅតាមអ្វីដែលទ្រឹស្តីបានកំណត់ទាំងស្រុងនោះទេ ពោលនៅតែមានបញ្ហាមិនប្រក្រតីមួយចំនួនកើតឡើងដែលនាំឲ្យការធ្វើប្រតិភូកម្មមិនអាចទទួលបានប្រសិទ្ធិភាពពេញលេញ។ ដូចនេះហើយដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើនេះ ទាមទារឲ្យមានការសិក្សាស្រាវជ្រាវ ដើម្បីស្រាយបំភ្លឺពីបញ្ហានេះឲ្យបានកាន់តែច្បាស់លាស់ថែមទៀត។

សារណានេះធ្វើការសិក្សាស្រាវជ្រាវដោយផ្អែកលើប្រភពឯកសារសំខាន់ៗមួយចំនួនដូចជា៖ លិខិតបទដ្ឋានគតិយុត្តនានា និងឯកសារសៀវភៅជាទ្រឹស្តី មកធ្វើជាមូលដ្ឋានក្នុងការស្រាវជ្រាវ។

ដើម្បីជួយសម្រួលដល់ការបកស្រាយប្រធានបទនេះឲ្យកាន់តែមានភាពច្បាស់លាស់ ខ្ញុំបាទបានបែងចែកជាពីរជំពូក គឺទ្រឹស្តីទូទៅ(ជំពូកទី ១) និងការអនុវត្តជាក់ស្តែងនៅកម្ពុជា(ជំពូកទី ២)។

# ជំពូកទី១

# ទ្រឹស្តីទូទៅ

ប្រតិភូកម្មអំណាច និងប្រតិភូកម្មហត្ថលេខានឹងត្រូវលើកយកមកសិក្សាក្នុងផ្នែកទី១ ហើយ អានុភាពគតិយុត្តនឹងត្រូវយកមកសិក្សាក្នុងផ្នែកទី២ ។

## ផ្នែកទី១

## លក្ខខណ្ឌនៃប្រតិភូកម្មអំណាច និងប្រតិភូកម្មហត្ថលេខា

ប្រតិភូកម្មអំណាច និងប្រតិភូកម្មហត្ថលេខាត្រូវគោរពលក្ខខណ្ឌរួម និងលក្ខខណ្ឌដោយឡែក។

### កថាខណ្ឌ ១ លក្ខខណ្ឌរួម

នៅក្នុងការធ្វើប្រតិភូកម្ម ទោះជាប្រតិភូកម្មអំណាចក្តី ឬ ជាប្រតិភូកម្មហត្ថលេខាក្តី ត្រូវឆ្លើយតបទៅនឹងលក្ខខណ្ឌដូចតទៅៈ

#### ក- ប្រតិភូកម្មត្រូវមានអត្ថបទចែង

ប្រតិភូកម្មអាចធ្វើទៅបាន ដោយស្តែងចេញច្បាស់លាស់ តាមរយៈរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទបញ្ជា ហើយប្រសិនបើវាមិនត្រូវផាត់ចេញដោយអត្ថបទទេ។ គ្មានប្រតិភូកម្មដោយគ្មានអត្ថបទចែងនោះទេ[២]។

ប្រតិភូកម្មត្រូវមានចែងដោយអត្ថបទ ហើយអត្ថបទនោះមិនត្រូវបានទាត់ចោលដោយស្តែងចេញច្បាស់លាស់ ឬដោយតុណ្ហីភាពនោះទេ។

ឧទាហរណ៍ មាត្រា២៨ ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានកំណត់ថា " *ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និងទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី។*

*ក្នុងពេលដែលព្រះមហាក្សត្រប្រឈួន ហើយត្រូវព្យាបាលព្រះរោគនៅបរទេស ក្នុងពេល*

[២] Conceil detat 30 juin 1961*procurer general de la Cour des comptes: Revue de droit public i1961, p. 845*

*នោះព្រះមហាក្សត្រ មានសិទ្ធិផ្ទេរអំណាចឡាយព្រះហស្ថលេខា នៅលើព្រះរាជក្រម ឬព្រះរាជក្រឹត្យខាងលើនេះទៅប្រមុខរដ្ឋស្តីទីចុះហត្ថលេខាជំនួសដោយព្រះរាជសារប្រគល់សិទ្ធិ"។*

ចំពោះនាយករដ្ឋមន្ត្រីវិញ មាត្រា១២៤ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣បានកំណត់ថា " *នាយករដ្ឋមន្ត្រីអាចរំលែកអំណាចរបស់ខ្លួនទៅឲ្យឧបនាយករដ្ឋមន្ត្រី ឬសមាជិកណាមួយនៃរដ្ឋាភិបាលបាន"*។ លើសពីនេះ មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ បានចែងថា " *ក្នុងពេលដែលនាយករដ្ឋមន្ត្រីអវត្តមាន ឧបនាយករដ្ឋមន្ត្រីទទួលការងារជំនួសតាមការប្រគល់សិទ្ធិចំពោះមុខពីនាយករដ្ឋមន្ត្រី"*។

### ខ- ប្រតិភូកម្មត្រូវសរសេរជាលាយលក្ខណ៍អក្សរ

ប្រតិភូកម្ម ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ( ចែងក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ ព្រះរាជសារប្រគល់សិទ្ធិ អនុក្រឹត្យ លិខិតប្រគល់សិទ្ធិ ប្រកាស ឬដីកាជាដើម) អត្ថបទទាំងនេះចង្អុលប្រាប់ដោយចំពោះមុខអ្នកធ្វើប្រតិភូកម្ម និងអ្នកទទួលប្រតិភូកម្ម។ មិនត្រឹមតែប៉ុណ្ណោះទេ អត្ថបទក៏កំណត់ផងដែរអំពីវិស័យដែលត្រូវផ្ទេរ និងកាលបរិច្ឆេទនៃប្រតិភូកម្ម។

ឧទាហរណ៍

ព្រះមហាក្សត្រ ធ្វើប្រតិភូកម្មតាមរយៈព្រះរាជក្រឹត្យ ឬព្រះរាជសារប្រគល់សិទ្ធិ ដូចមានចែងក្នុងមាត្រា២៨ថ្មី ដែលកំណត់ថា ព្រះមហាក្សត្រ មានសិទ្ធិផ្ទេរអំណាចឡាយព្រះហស្ថលេខា នៅលើព្រះរាជក្រម ឬព្រះរាជក្រឹត្យខាងលើនេះទៅប្រមុខរដ្ឋស្តីទីចុះហត្ថលេខាជំនួសដោយព្រះរាជសារប្រគល់សិទ្ធិ។

នាយករដ្ឋមន្ត្រី ធ្វើប្រតិភូកម្មតាមរយៈ លិខិតសិទ្ធិប្រទាន អនុក្រឹត្យ ឬសេចក្តីសម្រេច ជាក់ស្តែងក្នុងសេចក្តីសម្រេច លេខ ០២ របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៧ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចផ្ទេរសិទ្ធិជូន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទីនៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រីដែលត្រូវទៅអញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី១២ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធចាប់ពីថ្ងៃទី ១២ ខែមករា ឆ្នាំ ២០០៧ នៅទីក្រុងសេប៊ូ សាធារណរដ្ឋហ្វីលីពីន រហូតដល់ពេលសម្តេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ។

ប្រតិភូកម្មថ្នាក់ក្រសួងមានទម្រង់ជាលិខិតប្រគល់សិទ្ធិ ប្រកាស ឬ សិទ្ធិប្រទាន។

ឧទាហរណ៍ នាយករដ្ឋមន្ត្រី បានធ្វើប្រតិភូកម្មអំណាចឲ្យរដ្ឋមន្ត្រី ហើយរដ្ឋមន្ត្រីធ្វើប្រតិភូកម្មអំណាចបន្តទៅអភិបាលរាជធានី ខេត្ត (មាត្រា៤៣ អនុក្រឹត្យលេខ២២ ចុះថ្ងៃទី២៥ មីនា ឆ្នាំ ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់បានកំណត់ថា ការធ្វើប្រតិភូកម្មរបស់ក្រសួងមហាផ្ទៃទៅអោយអភិបាល ខេត្ត ក្រុង ត្រូវធ្វើតាមរយៈប្រកាសក្រសួង)។

អភិបាលរាជធានី ខេត្ត ក្រុង ធ្វើប្រតិភូកម្មតាមរយៈលិខិតប្រគល់សិទ្ធិ ឬ ដីកាខេត្ត ក្រុង ដូចមានចែងក្នុងមាត្រា៩៧ អនុក្រឹត្យ លេខ២១៦ស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក បានកំណត់ថា ក្នុងករណីអភិបាលក្រុងស្តីទីអវត្តមាន អភិបាលខេត្តត្រូវចេញដីកា ដើម្បីប្រគល់ភារកិច្ចជូនអភិបាលរងក្រុងមួយរូបឲ្យទទួលជាអភិបាលក្រុងស្តីទី។

មេឃុំ-ចៅសង្កាត់ ធ្វើប្រតិភូកម្មតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ។ យោងអនុក្រឹត្យលេខ ២៦ អនក្របក ចុះថ្ងៃ០២ មេសា ២០០២ មាត្រា២៧ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ មេឃុំ ចៅសង្កាត់អាចផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ ក្នុងការសម្រេចលើថវិកាទៅឲ្យជំទប់ ចៅសង្កាត់រងណាមួយរបស់រដ្ឋបាលឃុំ សង្កាត់។

### គ- ប្រតិភូកម្មត្រូវធ្វើឡើងដោយផ្នែក

ប្រតិភូកម្មត្រូវធ្វើឡើងដោយផ្នែក រឿងនេះចង់និយាយថា អាជ្ញាធរមួយនៅក្នុងក្របខណ្ឌនៃតួនាទីភារកិច្ចរបស់ខ្លួន មិនអាចដកខ្លួនចេញពីអំណាចទាំងអស់បានទេ។ រឿងនេះ នាំឲ្យមានភាពក្រឡាប់ចាក់ក្នុងលំដាប់នៃសមត្ថកិច្ច ហើយជាពិសេស ឈានទៅដល់ការលាលែងពីតំណែង(Conseil d'Etat du 8 février 1950, Chauvel)។

### ឃ- ប្រតិភូកម្មត្រូវធ្វើឡើងដោយស្តែងឡើងច្បាស់លាស់ និងជាក់លាក់

ប្រតិភូកម្ម ត្រូវធ្វើឡើងដោយស្តែងឡើងច្បាស់លាស់ និងជាក់លាក់ ឧទាហរណ៍ សេចក្តីសម្រេចលេខ ២៨ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០១៣របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំ រាជរដ្ឋាភិបាលបានកំណត់របៀបរបបការងារ និងបែងចែកភារកិច្ច ជូននាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រីយ៉ាងជាក់លាក់។

ឧទាហរណ៍ ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជានាយករដ្ឋមន្ត្រីស្តីទី ពេលនាយករដ្ឋមន្ត្រីអវត្តមាន ជួយការងារនាយករដ្ឋមន្ត្រីលើការងារសន្តិសុខជាតិ ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការជួញដូរមនុស្ស ដឹកនាំប្រតិបត្តិការទប់ស្កាត់ និងប្រឆាំងភាវរកម្ម ដឹកនាំគណៈកម្មាធិការជាតិកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការបំផ្លាញចោលអាវុធ ព្រមទាំងការងារភូមិ-ឃុំមានសុវត្ថិភាព។

## កថាខណ្ឌ ២ លក្ខខណ្ឌផ្ទាល់សម្រាប់ប្រភេទនីមួយៗ

ប្រតិភូកម្មអំណាច និងប្រតិភូកម្មហត្ថលេខាត្រូវគោរពតាមលក្ខខណ្ឌផ្ទាល់ដាច់ដោយឡែកពីគ្នា។

### ក- ប្រតិភូកម្មអំណាច

ប្រតិភូកម្មអំណាច (សមត្ថកិច្ច) ជានិច្ចជាកាល ត្រូវយល់ព្រមប្រគល់ទៅឲ្យអាជ្ញាធរមួយដែលកំណត់ជាក់លាក់ដោយរបៀបអរូបី ហើយមិនមែនលក្ខណៈជាបុគ្គលនោះទេ ( Intuitu Personae )

ឧទាហរណ៍ ក្រុមប្រឹក្សាឃុំ ធ្វើប្រតិភូកម្មអំណាចរបស់ខ្លួនមួយចំនួន ទៅឲ្យមេឃុំ[៣] នេះជាលក្ខណៈខុសគ្នាខ្លាំង បើប្រៀបធៀបទៅនឹងប្រតិភូកម្មមុខងារ។ ផលវិបាកនៃការរៀបចំបង្កើតឲ្យមានប្រតិភូកម្មមុខងារ ឬអំណាច មិនដូចគ្នានោះទេ ពោលប្រតិភូកម្មមុខងារ គឺមានលក្ខណៈជាបុគ្គល (Intuitu Personae) ។

ចំណែកនៅក្នុងប្រទេសយើងវិញក៏ដូចគ្នានេះដែរ ព្រះមហាក្សត្រទ្រង់រំលែកអំណាចរបស់ព្រះអង្គទៅឲ្យប្រមុខរដ្ឋស្តីទីតាមរយៈព្រះរាជក្រឹត្យ ឬព្រះរាជសារប្រទានសិទ្ធិ ដូចមានចែងក្នុងមាត្រា ២៨ថ្មី នៃរដ្ឋធម្មនុញ្ញប្រទេសកម្ពុជាឆ្នាំ១៩៩៣ ដែលបានកំណត់ថា "*...ក្នុងពេលដែលព្រះមហាក្សត្រប្រឈួន ហើយត្រូវព្យាបាលរោគនៅបរទេស ក្នុងពេលនោះព្រះមហាក្សត្រមានសិទ្ធិផ្ទេរអំណាចឡាយព្រះហស្តលេខា នៅលើព្រះរាជក្រម ឬព្រះរាជក្រឹត្យខាងលើនេះទៅប្រមុខរដ្ឋស្តីទីខុះហត្ថលេខាជំនួសដោយព្រះរាជសារប្រគល់សិទ្ធិ*"

អនុក្រឹត្យលេខ ៤៩៧របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០១៣ បានសម្រេចធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជ-ការដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ ក្នុងការចេញដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីរាជការ

[៣] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ លេខ នស/រកម/០៣១/០៥ ,១៩ មីនា ២០០១, មាត្រា៥១

ស៊ីវិលដែលបំពេញការងារនៅតាមមន្ទីរ អង្គភាព និងការិយាល័យរបស់ក្រសួង ស្ថាប័ននានានៅថ្នាក់ក្រោមជាតិ។

ប្រកាសលេខ ១៨៨៤ របស់ក្រសួងមហាផ្ទៃ បានធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់។ មិនមែនជាករណីនេះទាល់តែសោះនៅក្នុងប្រតិភូកម្មអំណាចរវាងក្រុមប្រឹក្សាឃុំ និងមេឃុំ ឬរវាងក្រុមប្រឹក្សារាជធានី ខេត្ត និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្តកាលណាវាជាប្រតិភូកម្មអំណាច ប្រសិនបើក្រុមប្រឹក្សាចង់ងាកមករកសេចក្តីសម្រេចមួយឡើងវិញ ដែលជាកម្មវត្ថុនៃប្រតិភូកម្មមួយនោះ ចាំបាច់ត្រូវជជែក ពិភាក្សាអនុម័តឡើងវិញដែលអាចអនុញ្ញាតឲ្យក្រុមប្រឹក្សាសម្រេចបែបនេះ ឬបែបនោះឡើងវិញនៅក្នុងវិស័យសមត្ថកិច្ចមួយដែលត្រូវធ្វើប្រតិភូកម្ម ឬមួយទៅឲ្យមេឃុំ ឬអ្នកណាផ្សេងទៀត ។ នេះជាចំណុចដ៏សំខាន់មួយដែលត្រូវបានបញ្ជាក់ឲ្យច្បាស់ ដោយយុត្តិសាស្ត្រតុលាការកំពូលនៃប្រទេសបារាំង (Conseil d'Etat) ។ នេះគឺជាការបង្កើតនូវអ្វីដែលគេបានហៅថា "ភាពស្របនិយមនៃទម្រង់"។ សេចក្តីសម្រេចមួយនឹងអនុញ្ញាតឲ្យមេឃុំអនុវត្តនៅក្នុងវិស័យបែបនេះឬបែបនោះ ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ ប្រសិនបើក្រុមប្រឹក្សា ចង់ចេញសេចក្តីសម្រេចមួយនៅក្នុងវិស័យសមត្ថកិច្ចនេះ ចាំបាច់ត្រូវងាកមកមើល សេចក្តីសម្រេចស្តីពីប្រតិភូកម្មអំណាចឡើងវិញ ចំពោះអង្គការប្រតិបត្តិដែលកាន់កាប់អំណាចនេះ(ប្រធាន ក្រុមប្រឹក្សា ឃុំ) ។

តាមវិទ្យាស្ថានជាតិស្តីពី សុខភាព និងការស្រាវជ្រាវថ្នាំពេទ្យ (នាយកដ្ឋានកិច្ចការច្បាប់ចេញផ្សាយថ្ងៃ១៣ ខែមិនា ឆ្នាំ២០១២) ប្រតិភូកម្មអំណាចចំពោះអាជ្ញាធររដ្ឋបាលគឺជាការដែលដកខ្លួនចេញពីអំណាចមួយ ឬច្រើនរបស់ខ្លួននៅក្នុងព្រំដែនច្បាប់ ឬបទបញ្ជា ជាប្រយោជន៍ដល់អាជ្ញាធរមួយផ្សេងទៀតដែលនឹងអនុវត្តវាជាជំនួសឲ្យខ្លួន។ ប្រតិភូកម្មអំណាចធ្វើការផ្ទេរសមត្ថកិច្ចដ៏ពិតប្រាកដមួយ ឧទាហរណ៍ អាជ្ញាធរដែលធ្វើប្រតិភូកម្មលែងមានអំណាចនេះទៀតហើយ ជាប្រយោជន៍ដល់អ្នកទទួលប្រតិភូកម្ម។ អាជ្ញាធរដែលធ្វើប្រតិភូកម្ម ក្លាយជាអាជ្ញាធរអសមត្ថកិច្ចក្នុងវិស័យដែលបានធ្វើប្រតិភូកម្ម ហើយអាជ្ញាធរដែលទទួលប្រតិភូកម្មក្លាយជាអាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យដែលផ្ទេរ។ អាជ្ញាធរធ្វើប្រតិភូកម្មមិនទទួលខុសត្រូវលើសេចក្តីសម្រេចដែលចេញដោយអាជ្ញាធរទទួលប្រតិភូកម្មទេ។ ប្រតិភូកម្មអំណាចត្រូវចាត់ចែងទៅឲ្យមុខងារមួយ វាត្រូវប្រគល់ឲ្យក្នុងឋានៈនេះដោយរបៀបអរូបី ហើយវាទាក់ទងទៅនឹងអ្នកដែលមានមុខងារមួយចំនួន។ ប្រតិភូកម្មអំណាចត្រូវធ្វើឡើងជាប្រយោជន៍ដល់អ្នកមានមុខងារកំណត់ជាក់លាក់ ហើយមិនមែនជាប្រយោជន៍ដល់បុគ្គលណាមួយទេ។

តាមសៀវភៅនីតិរដ្ឋបាលរបស់សាស្ត្រាចារ្យ ឌឿក ពិដោរ ចេញផ្សាយឆ្នាំ២០០៧ បោះពុម្ពផ្សាយដោយរោងពុម្ពអង្គរ ប្រតិភូកម្មអំណាច គឺជាការផ្ទេរៈ

- អំណាចពីអាជ្ញាធររដ្ឋបាលមានសមត្ថកិច្ចមួយ ទៅអាជ្ញាធររដ្ឋបាលមានសមត្ថកិច្ចមួយទៀត ហើយមិនមែនពីបុគ្គលទៅបុគ្គលទេ ឧទាហរណ៍ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចធ្វើប្រតិភូកម្មរបស់ខ្លួនទៅឲ្យអភិបាលរាជធានីខេត្ត ។
- ការផ្ទេរអំណាចនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរច្បាស់លាស់ដោយកំណត់ពីវិស័យឲ្យបានច្បាស់លាស់។
- អាជ្ញាធរដែលផ្ទេរឬធ្វើប្រតិភូកម្មក្លាយជាអសមត្ថកិច្ចក្នុងវិស័យដែលផ្ទេរ ហើយអាជ្ញាធរដែលទទួលការផ្ទេរក្លាយជាអាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យដែលផ្ទេរ។
- ការផ្ទេរអំណាចនេះមិនមានលក្ខណៈទាំងស្រុងទេ គឺផ្ទេរដោយផ្នែក។
- អាជ្ញាធរទទួលការផ្ទេរអាចធ្វើប្រតិភូកម្មបន្តទៅឲ្យអាជ្ញាធរផ្សេងទៀតបាន ឧទាហរណ៍ ពេលអភិបាលរាជធានីខេត្តទទួលប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលរាជធានីខេត្តអាចធ្វើប្រតិភូកម្មអំណាចនេះទៅ អភិបាលស្រុក ឬមេឃុំទៀតបាន។
- អាជ្ញាធរដែលផ្ទេរ មិនទទួលខុសត្រូវពីសេចក្ដីសម្រេចដែលចេញដោយអាជ្ញាធរទទួលប្រតិភូកម្មបន្ថែមលើនេះអាជ្ញាធរទទួលការផ្ទេរ នៅតែស្ថិតក្រោមអំណាចឋានានុក្រមរបស់អាជ្ញាធរដែលធ្វើប្រតិភូកម្ម។
- កិច្ចដែលសម្រេចពីប្រតិភូកម្មត្រូវចុះផ្សាយ មុននឹងដាក់ឲ្យអនុវត្ត។

### ខ- ប្រតិភូកម្មហត្ថលេខា

ប្រតិភូកម្មហត្ថលេខាមានអានុភាព តែដើម្បីសម្រាលបន្ទុកជាលក្ខណៈសម្ភារៈ អ្នកផ្ទេរចេញពីភារកិច្ចរបស់ខ្លួនមួយផ្នែក ដោយអនុញ្ញាតឲ្យអ្នកផ្ទេរនេះ ចាត់តាំងបុគ្គលម្នាក់ដែលនឹងចេញសេចក្ដីសម្រេចក្នុងនាមខ្លួន ។

ឧទាហរណ៍ក្នុងសេចក្ដីសម្រេចលេខ២៨ របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការកំណត់របៀបរបបការងារ និងការបែងចែងភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល បានកំណត់របៀបរបបការងារ និងបែងចែកភារកិច្ច ជូននាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស សំដៅធានាការអនុវត្តច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋមានការបែងចែកជាបន្តបន្ទាប់ ដើម្បីកំណត់ពីមុខងារឧបនាយករដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រីមួយចំនួន។

សមាសភាពរបស់ឧបនាយករដ្ឋមន្ត្រីមាន ៖

–**ឯកឧត្តម ស ខេង** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជានាយករដ្ឋមន្ត្រីស្តីទី ពេលនាយករដ្ឋមន្ត្រីអវត្តមាន ជួយការងារនាយករដ្ឋមន្ត្រីលើការងារសន្តិសុខជាតិ ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការជួញដូរមនុស្ស ដឹកនាំប្រតិបត្តិការទប់ស្កាត់ និងប្រឆាំងភាវរកម្ម ដឹកនាំគណៈកម្មាធិការជាតិកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការបំផ្លាញចោលអាវុធ ព្រមទាំងការងារភូមិ-ឃុំមានសុវត្ថិភាព។

–**ឯកឧត្តម សុខ អាន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកសម្របសម្រួលកិច្ចការសម្រេចគណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី និងបណ្តាឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រីក្នុងការតាមដាន សម្របសម្រួល ដំណើរការតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ដឹកនាំផ្ទាល់អាជ្ញាធរប្រេងកាតកម្ពុជា អាជ្ញាធរអប្សរា គណៈកម្មការយូណេស្កូ និងក្រុមប្រឹក្សាអ្នកច្បាប់ ព្រមទាំងជួយនាយករដ្ឋមន្ត្រីក្នុងការរៀបចំចម្លើយតបនឹងសំណួររបស់សមាជិករដ្ឋសភា ស្របតាមនីតិវិធីដូចមានចែងក្នុងមាត្រា៩៦នៃរដ្ឋធម្មនុញ្ញ។

–**ឯកឧត្តម ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកការងារការពារជាតិ ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រីក្នុងការបញ្ជាកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដឹកនាំកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងទទួលសិទ្ធិពីនាយករដ្ឋមន្ត្រីក្នុងការបញ្ជាអង្គភាពពិសេសប្រឆាំងភេរវកម្ម ក្នុងពេលនាយករដ្ឋមន្ត្រីអវត្តមាន។

–**ឯកឧត្តម គាត ឈន់** ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកប្រចាំការដោះស្រាយការងារប្រចាំថ្ងៃជំនួសនាយករដ្ឋមន្ត្រី ទទួលបន្ទុកការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ការងារអភិវឌ្ឍវិស័យឯកជន ការងារភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍជាមួយតួអង្គអភិវឌ្ឍនដែលមានការពាក់ព័ន្ធ ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រីក្នុងការពិនិត្យ និងសម្រេចលើការងាររបស់ ច្រកចេញ ចូលតែមួយ នៃក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា លើកលែងការងារដែលមានវេទយិតភាពខ្ពស់ ដែលតម្រូវឲ្យសុំការណែនាំ ឬការសម្រេចពីនាយករដ្ឋមន្ត្រី និងទទួលសិទ្ធិពីនាយករដ្ឋមន្ត្រីក្នុងការពិនិត្យ និងសម្រេចលើសំណើសំណុំកូន និងការលាសញ្ជាតិ។

–**ឯកឧត្តម ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេស និងសហប្រតិបត្តិការអន្តរជាតិទូទៅ។

–**លោក ជំទាវ ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រី លើការងារអធិការកិច្ច និងសវនកម្ម ព្រមទាំងជួយនាយករដ្ឋមន្ត្រីលើការងារសង្គម។

-**ឯកឧត្តម ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំផ្ទាល់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ព្រមទាំងជួយនាយករដ្ឋមន្ត្រីលើការងារសង្គមទប់ស្កាត់ និងប្រឆាំងអំពើពុករលួយ។

-**ឯកឧត្តមយឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ។

-**ឯកឧត្តម កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំផ្ទាល់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

រីឯសមាសភាពទេសរដ្ឋមន្ត្រីរួមមានដូចជា៖

-**ឯកឧត្តម ញឹម វណ្ណដា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

-**ឯកឧត្តម យុន ហាំង** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានប្រចាំការអាជ្ញាធរជាតិ ដោះស្រាយទំនាស់ដីធ្លី។

-**ឯកឧត្តម លី ធុជ** ទេសរដ្ឋមន្ត្រីទទួលបន្ទុកជាអនុប្រធានទី២ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងទទួលបន្ទុកESCAP។

-**ឯកឧត្តម ចន្ទ សារុន** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ។

-**ឯកឧត្តម ឱម យិនទៀង** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំគណៈកម្មាធិការសិទ្ធិមនុស្សរបស់រាជរដ្ឋាភិបាល និង អង្គភាពប្រឆាំងអំពើពុករលួយ។

-**ឯកឧត្តម អៀង ម៉ូលី** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍។

-**ឯកឧត្តម វ៉ា គឹមហុង** ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការព្រំដែន។

-**ឯកឧត្តម យឹម ណុលឡា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកការងារក្រុមសង្កេតការណ៍សេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌។

-**ឯកឧត្តម សើរី កុសល** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីអំពីការងារវប្បធម៌។

-**ឯកឧត្តម ជិន ប៊ុនស៊ាន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកជាអនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ។

តាមរយៈសេចក្តីសម្រេចនេះបានបង្ហាញឲ្យឃើញថាប្រតិភូកម្មបានធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានបែងចែកតួនាទីយ៉ាងច្បាស់លាស់។

ផ្ទុយទៅនឹងប្រតិភូកម្មអំណាច ប្រតិភូកម្មហត្ថលេខាមិនមានការផ្ទេរសមត្ថកិច្ចណាមួយឡើយ។

ដូច្នេះ ប្រតិភូកម្មហត្ថលេខា មិនធ្វើឲ្យអាជ្ញាធរ ដែលធ្វើប្រតិភូកម្ម បាត់បង់អំណាច ឬការអនុវត្តអំណាចរបស់ខ្លួនឡើយ អាជ្ញាធរដែលធ្វើប្រតិភូកម្មរក្សាការទទួលខុសត្រូវរបស់ខ្លួន ដែលនៅតែពេញលេញ និងទាំងស្រុង ចំពោះគ្រប់កិច្ចដែលចេញដោយអ្នកទទួលប្រតិភូកម្ម។ អ្នកទទួលប្រតិភូកម្មមាននីតិសម្បទាក្នុងការអនុវត្តអំណាចរបស់អ្នកធ្វើប្រតិភូកម្ម ប៉ុន្តែមិនអាចប្រើអំណាចនេះទេ។ ប្រតិភូកម្មហត្ថលេខា អាចត្រូវបានយល់ព្រមប្រគល់ទៅឲ្យបុគ្គលច្រើនបាន។ ប្រតិភូកម្មហត្ថលេខាត្រូវយល់ព្រមធ្វើឡើងដោយបុគ្គលមួយទៅបុគ្គលមួយទៀត ។ រាល់ការផ្លាស់ប្តូរនៅក្នុងបុគ្គលនៃអ្នកទទួលប្រតិភូកម្ម ឬអ្នកធ្វើប្រតិភូកម្ម នឹងនាំឲ្យប្រតិភូកម្មក្លាយជាមោឃៈ ប្រតិភូកម្មនេះ អាចត្រូវជូនដំណឹងទៅបុគ្គលដែលពាក់ព័ន្ធ ។ ជាសរុបប្រតិភូកម្មហត្ថលេខា គឺជាការផ្ទេរៈ

- –ហត្ថលេខាពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ ឧទាហរណ៍ រដ្ឋមន្ត្រី ទៅសហការី របស់ខ្លួនណាម្នាក់ពោលគឺទៅរដ្ឋលេខាធិការណាម្នាក់ តែមិនមែនពីអាជ្ញាធរមួយ ទៅអាជ្ញាធរមួយទេ។
- –ការផ្ទេរនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជាក់លាក់
- –អ្នកធ្វើប្រតិភូកម្មនៅតែជាអ្នកទទួលខុសត្រូវលើសេចក្តីសម្រេចដដែល
- –អ្នកទទួលការផ្ទេរ មិនអាចផ្ទេរហត្ថលេខាបន្តទៀតបានទេ។

### កថាខណ្ឌ៣ ប្រៀបធៀបប្រតិភូកម្មអំណាច និងប្រតិភូកម្មហត្ថលេខា

ក្រោយពីធ្វើការបកស្រាយ អំពីប្រតិភូកម្មទាំងពីរនេះរួចមក យើងអាចសង្ខេបបានជាតារាងមួយដើម្បីប្រៀបធៀបប្រតិភូកម្មទាំងពីរនេះ។

*តារាងសង្ខេបនៃការប្រៀបធៀបរវាងប្រតិភូកម្មអំណាច និងប្រតិភូកម្មហត្ថលេខា*

| | **ប្រតិភូកម្មអំណាច** | **ប្រតិភូកម្មហត្ថលេខា** |
|---|---|---|
| **ធ្វើឡើង** | ➢ដោយអាជ្ញាធរមួយទៅអាជ្ញាធរមួយទៀត។ | ដោយបុគ្គលមួយទៅបុគ្គលមួយ ដោយរដ្ឋមន្ត្រី ទៅសហការីរបស់រដ្ឋមន្ត្រីផ្ទាល់ ( ខុទ្ទកាល័យ ឬប្រធានមន្ទីរជំនាញ)។ |
| **លក្ខណៈ** | ➢ អរូបីមិនចំពោះបុគ្គល។<br>➢ មិនប្រែប្រួលទៅតាមការផ្លាស់ប្តូរ | ➢ ច្បាស់លាស់ដោយចង្អុលបង្ហាញពីបុគ្គលទទួល។<br>➢ ប្រែប្រួលឬបញ្ចប់ទៅតាមការផ្លាស់ |

| | | |
|---|---|---|
| **លក្ខណៈ(ត)** | អាជ្ញាធរដែលធ្វើប្រតិភូកម្ម ឬអាជ្ញាធរដែលទទួលប្រតិភូកម្មឡើយ ប្រសិនបើសេចក្តីសម្រេចធ្វើប្រតិភូកម្មនោះមិនបានកែប្រែ។<br>➢ អាជ្ញាធរដែលធ្វើប្រតិភូកម្មផ្ទេរមួយភាគនូវអំណាចរបស់ខ្លួន (គាត់មិនអាចអនុវត្តសិទ្ធិរបស់គាត់បានទៀតទេ)។<br>➢ អាជ្ញាធរដែលធ្វើប្រតិភូកម្ម និងអាជ្ញាធរដែលទទួលប្រតិភូកម្មអនុវត្តកាតព្វកិច្ចដាច់ដោយឡែកពីគ្នា។ | ប្តូរអាជ្ញាធរដែលធ្វើប្រតិភូកម្ម ឬបុគ្គល ដែលទទួលប្រតិភូកម្ម។<br>➢ អាជ្ញាធរដែលធ្វើប្រតិភូកម្មគ្រាន់តែត្រូវបានដកបន្ទុកការងារជាក់ស្តែងមួយចំណែកប៉ុណ្ណោះ (គាត់អាចអនុវត្តសមត្ថកិច្ចផ្ទេរនោះបានគ្រប់ពេលវេលា)។<br>➢ អាជ្ញាធរដែលធ្វើប្រតិភូកម្មឬបុគ្គលដែលទទួលប្រតិភូកម្មអនុវត្តភារកិច្ចរួមគ្នា។ |
| **តម្លៃនៃសេចក្តីសម្រេច** | ➢ អនុវត្តនៅក្នុងឋានានុក្រមរបស់ខ្លួន | ➢ ដូចសេចក្តីសម្រេចរបស់អាជ្ញាធរដែលធ្វើប្រតិភូកម្ម។ |
| **ការទទួលខុសត្រូវ** | ➢ អាជ្ញាធរដែលទទួលប្រតិភូកម្មទទួលខុសត្រូវដោយផ្ទាល់ក្នុងការអនុវត្តអំណាចដែលផ្ទេរ។ | ➢បុគ្គលដែលធ្វើប្រតិភូកម្មជាអ្នកទទួលខុសត្រូវនូវការអនុវត្តភារកិច្ចដែលផ្ទេរឱ្យទៅបុគ្គលដែលទទួលប្រតិភូកម្ម។ |
| **លទ្ធភាពធ្វើប្រតិភូកម្មបន្ត** | ➢ អាចធ្វើប្រតិភូកម្មហត្ថអំណាចបន្ត។ | ➢ គ្មានលទ្ធភាពធ្វើប្រតិភូកម្មហត្ថលេខាបន្ត។ |

# ផ្នែកទី ២
# អានុភាពគតិយុត្តនៃប្រតិភូកម្ម

នៅក្នុងការអនុវត្តប្រតិភូកម្មសមត្ថកិច្ចនេះមានការចូលរួមអនុវត្តពីតួអង្គបីរួមមាន ទីមួយអាជ្ញាធរ ឬអ្នកដែលធ្វើប្រតិភូកម្ម ទីពីរ អាជ្ញាធរ ឬអ្នកដែលទទួលប្រតិភូកម្ម និងទីបី គឺប្រជាពលរដ្ឋដែលជាអ្នកចូលរួមអនុវត្ត។

## កថាខណ្ឌ១ អានុភាពគតិយុត្តនៃប្រតិភូកម្ម ចំពោះអាជ្ញាធរដែលធ្វើប្រតិភូកម្ម

### ក- នៅក្នុងប្រតិភូកម្មអំណាច

ជាទូទៅនៅពេលដែលអាជ្ញាធរធ្វើប្រតិភូកម្ម បានធ្វើប្រតិភូកម្មអំណាចរបស់ខ្លួនទៅឲ្យអាជ្ញាធរ ដែលទទួលប្រតិភូកម្មហើយនោះ អាជ្ញាធរនេះមិនអាចអនុវត្តអំណាចនោះបានទេ អំណាចនោះត្រូវផ្ទេរទាំងស្រុងទៅឲ្យអាជ្ញាធរដែលទទួលប្រតិភូកម្ម។ ម្យ៉ាងវិញទៀត ការអនុវត្តអំណាចនេះអាជ្ញាធរធ្វើប្រតិភូកម្ម ត្រូវបានរួចខ្លួនពីការទទួលខុសត្រូវទាំងឡាយដែលកើតមានជាយថាហេតុពេលគ្មានជាប់ពាក់ព័ន្ធក្នុងការអនុវត្តទេ។ ប៉ុន្តែ ទោះបីជាគោលការណ៍បានលើកឡើងយ៉ាងណាក៏ដោយ ក៏នៅក្នុងការអនុវត្តជាក់ស្តែងអាជ្ញាធរធ្វើប្រតិភូកម្មនៅតែរក្សាអំណាចមួយដែរ នោះគឺអំណាចឋានានុក្រម ដែលជាអំណាចពេញច្បាប់របស់អាជ្ញាធរដែលធ្វើប្រតិភូកម្ម អំណាចនេះពុំចាំបាច់មានលក្ខខណ្ឌទេ ពោលទោះបីជាមិនមានអត្ថបទច្បាប់អ្វីចែងក៏អាចអនុវត្តបានដែរ។

### ខ- នៅក្នុងប្រតិភូកម្មហត្ថលេខា

ក្នុងប្រតិភូកម្មហត្ថលេខាវិញ អ្នកដែលធ្វើប្រតិភូកម្មនៅតែជាម្ចាស់សមត្ថកិច្ច អ្នកដែលធ្វើប្រតិភូកម្មអាច យកសមត្ថកិច្ចដែលបានផ្ទេរនោះមកអនុវត្តដោយខ្លួនផ្ទាល់បានគ្រប់ពេលវេលា ដោយមិនបាច់ធ្វើការកែប្រែ ឬ បញ្ចប់ប្រតិភូកម្មអ្វីទេ។ ទន្ទឹមនឹងនេះ ក្នុងការអនុវត្តជាក់ស្តែងអ្នកដែលធ្វើប្រតិភូកម្មទទួលបាននូវអំណាចមួយយ៉ាងធំ ក្នុងការអនុវត្តប្រតិភូកម្មហត្ថលេខារួមជាមួយអ្នកដែលទទួលប្រតិភូកម្មអំណាច នោះគឺជាអំណាចជំនួសសេចក្តីសម្រេច។ អំណាចជំនួសនេះ គឺជាអំណាចដែលផ្តល់ឲ្យទៅ អ្នកដែលធ្វើប្រតិភូកម្ម នៅពេលដែលអ្នកដែលធ្វើប្រតិភូកម្ម យល់ឃើញថា សេចក្តីសម្រេចណាមួយរបស់ថ្នាក់ក្រោមផ្ទុយនឹងគោលការណ៍របស់ខ្លួន ឬមិនស្របតាមនិយាមនៃច្បាប់ អ្នកដែលធ្វើប្រតិភូកម្មមានសិទ្ធិចេញសេចក្តីសម្រេចមួយទៀត ដែលយកមកជំនួសសេចក្តីសម្រេចរបស់អ្នកក្រោមបង្គាប់ដោយផ្ទាល់តែម្តង ហើយអ្នកដែលទទួលប្រតិភូកម្មពុំមានសិទ្ធិជំទាស់

បានឡើយ។ មិនត្រឹមតែប៉ុណ្ណោះទេ សេចក្តីសម្រេចដែលបានចេញហើយដោយអ្នកដែលទទួលប្រតិភូកម្មត្រូវឈប់អនុវត្ត គឺគេត្រូវអនុវត្តសេចក្តីសម្រេចរបស់អ្នកដែលធ្វើប្រតិភូកម្មដែលបានចេញជំនួសនោះវិញ។

ក្រៅពីសិទ្ធិ និងអំណាចដែលទទួលបានអ្នកដែលធ្វើប្រតិភូកម្មក៏មានកាតព្វកិច្ចមួយចំនួនទៀតដែរ គឺត្រូវធានាខុសត្រូវទាំងស្រុង រួមទាំងការអនុវត្តសេចក្តីសម្រេច និងការទទួលខុសត្រូវនូវកំហុសឆ្គងណាមួយដែលកើតឡើងជាយថាហេតុចំពោះសេចក្តីសម្រេចដែលទាក់ទងនឹងសមត្ថកិច្ចដែលបានធ្វើប្រតិភូកម្មនេះ។ ការទទួលខុសត្រូវនេះ មិនមែនត្រឹមតែចំពោះទង្វើដែលអ្នកដែលធ្វើប្រតិភូកម្មបានធ្វើដោយផ្ទាល់នោះទេគឺថែមទាំងទទួលខុសត្រូវទង្វើរបស់អ្នកទទួលប្រតិភូកម្មទៀតផង។

## កថាខណ្ឌ២ អានុភាពគតិយុត្តនៃប្រតិភូកម្ម ចំពោះអាជ្ញាធរដែលទទួលប្រតិភូកម្ម

### ក- នៅក្នុងប្រតិភូកម្មអំណាច

ដូចដែលបានរៀបរាប់ខាងលើហើយប្រតិភូកម្មអំណាច គឺតម្រូវឲ្យអាជ្ញាធរដែលធ្វើប្រតិភូកម្មផ្ទេរអំណាចទាំងស្រុងទៅឲ្យអាជ្ញាធរដែលទទួលប្រតិភូកម្ម ដូច្នេះ អាជ្ញាធរដែលទទួលប្រតិភូកម្មនឹងក្លាយទៅជាម្ចាស់អំណាចដែលបានផ្ទេរនោះ បានន័យថាអាជ្ញាធរដែលធ្វើប្រតិភូកម្មគ្មានពាក់ព័ន្ធជាមួយការអនុវត្តអំណាចដែលបានផ្ទេរនោះទេ។ ជាមួយនឹងអំណាចដែលទទួលបាននេះ យុត្តិសាស្ត្របានផ្តល់លទ្ធភាពដល់អាជ្ញាធរដែលទទួលប្រតិភូកម្មក្នុងការធ្វើប្រតិភូកម្មបន្ត ប៉ុន្តែ ត្រូវតែមានការអនុញ្ញាតពីអត្ថបទច្បាប់សិន។ ប៉ុន្តែ ការអនុវត្តអំណាចនោះត្រូវធ្វើឡើងក្នុងក្របខ័ណ្ឌឋានានុក្រមរបស់អាជ្ញាធរដែលទទួលប្រតិភូកម្មមិនមែនក្នុងឋានានុក្រមរបស់អាជ្ញាធរដែលធ្វើប្រតិភូកម្មទេ។ ជាក់ស្តែង តាមអនុក្រឹត្យលេខ៩៩៧ នៃរាជរដ្ឋាភិបាលកម្ពុជា ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិល ដែលបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្តចេញដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅតាមមន្ទីរ អង្គភាព និងការិយាល័យរបស់ក្រសួង ស្ថាប័ននានានៅថ្នាក់ក្រោមជាតិ។ នៅក្នុងការអនុវត្តប្រតិភូកម្មអំណាច អាជ្ញាធរដែលទទួលប្រតិភូកម្ម អនុវត្តក្រោមការទទួលខុសត្រូវរបស់ខ្លួនឯងផ្ទាល់ ទាំងក្នុងការអនុវត្ត និងក្នុងករណីប្រព្រឹត្តកំហុស។ ហើយការប្រព្រឹត្តកំហុសជាក់ស្តែង

អាជ្ញាធរដែលទទួលប្រតិភូកម្មអាចទទួលរងនូវការដាក់ពិន័យផ្នែករដ្ឋបាល និងជួសជុលការខូចខាតដល់ជនរងគ្រោះដោយសារកំហុសដែលបានប្រព្រឹត្តនោះ។ បន្ថែមទៅលើនេះផងដែរ ទោះជាប្រតិភូកម្មបានបញ្ឈប់ពីតំណែងមន្ត្រីរាជការក៏ដោយ ក៏មិនមែនជាមូលហេតុនៃការបញ្ចប់ប្រតិភូកម្មអំណាចដែរ។ ការធ្វើប្រតិភូកម្មនៅតែមានដដែល ហើយវានឹងបានទៅដល់អ្នកដែលមកកាន់តំណែងថ្មី ប្រសិនបើអាជ្ញាធរដែលធ្វើប្រតិភូកម្មមិនបានបញ្ចប់ប្រតិភូកម្មនោះទេ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែងវាមិនដូច្នេះទេតួនាទីត្រូវបញ្ចប់អ្វីៗ ក៏ត្រូវបញ្ចប់ដែរស្មូម្បីតែប្រតិភូកម្ម។

### ខ- នៅក្នុងប្រតិភូកម្មហត្ថលេខា

ដោយប្រតិភូកម្មហត្ថលេខាបានរក្សាទុកដដែលនូវសមត្ថកិច្ចរបស់អ្នកធ្វើប្រតិភូកម្ម ក្នុងករណីនេះអ្នកទទួលប្រតិភូកម្មអាចអនុវត្ត ក្នុងនាមគ្រាន់តែជាតំណាងឲ្យអ្នកធ្វើប្រតិភូកម្ម ប៉ុណ្ណោះ ទោះបីជាយ៉ាងណាក៏ដោយ អ្នកទទួលប្រតិភូកម្មអនុវត្តសមត្ថកិច្ចដោយឯករាជ្យដែរ មិនមែនតាមបញ្ញារបស់អ្នកដែលធ្វើប្រតិភូកម្មទេ ព្រោះតែអ្នកដែលធ្វើប្រតិភូកម្មជាម្ចាស់សមត្ថកិច្ច។ ដូច្នេះហើយបានជាទង្វើរបស់អ្នកទទួលប្រតិភូកម្ម រួចផុតពីការទទួលខុសត្រូវ និងការធានាក្នុងការអនុវត្ត។ ប៉ុន្តែ ដើម្បីឲ្យរួចផុតពីកាតព្វកិច្ចខាងលើនេះ មុននឹងចុះហត្ថលេខាក្នុងការចេញសេចក្តីសម្រេចអ្នកដែលទទួលប្រតិភូកម្ម ចាំបាច់ត្រូវដាក់ជាដាច់ខាតនូវពាក្យ "ជ+ហាន:តួនាទីរបស់អ្នកធ្វើប្រតិភូកម្ម" ឬ " តប+ហាន: ឬតួនាទីរបស់អ្នកធ្វើប្រតិភូកម្ម" រួចហើយទើបដាក់តួនាទីរបស់ខ្លួនឯង និងចុះហត្ថ-លេខាពីលើឈ្មោះរបស់ខ្លួន ធ្វើដូច្នេះមានន័យថា អ្នកទទួលប្រតិភូកម្មគ្រាន់តែចុះហត្ថលេខាក្នុងនាមឲ្យអ្នកធ្វើប្រតិភូកម្មតែប៉ុណ្ណោះ ក្នុងករណីកង្វះការចង្អុលបង្ហាញនេះ បានន័យថាអ្នកទទួលប្រតិភូកម្មចុះហត្ថលេខាក្នុងនាមផ្ទាល់ និង ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួនផ្ទាល់ផងដែរ។

## កថាខណ្ឌ៣ អានុភាពគតិយុត្តចំពោះប្រជាពលរដ្ឋ

ដោយសេចក្តីសម្រេចធ្វើប្រតិភូកម្មជាកិច្ចការផ្ទៃក្នុងរបស់រដ្ឋបាល ប្រជាពលរដ្ឋសាមញ្ញមិនអាចពាក់ព័ន្ធទេ។ ចំពោះសេចក្តីសម្រេចរបស់ប្រតិភូកម្មវិញ ក្នុងការអនុវត្តសមត្ថកិច្ចដែលបានធ្វើប្រតិភូកម្ម ចាំបាច់វាត្រូវតែពាក់ព័ន្ធជាមួយប្រជាពលរដ្ឋមិនខាន ព្រោះសេចក្តីសម្រេចនោះយកទៅប្រើប្រាស់ចំពោះប្រជាពលរដ្ឋ។ ប៉ុន្តែ មិនមែនមានន័យថា រាល់សេចក្តីសម្រេចនៃប្រតិភូកម្មទាំងអស់ ត្រូវតែយកទៅប្រើប្រាស់ចំពោះប្រជាពលរដ្ឋនោះទេ មានសេចក្តីសម្រេចខ្លះក៏មិននៅជាប់ពាក់ព័ន្ធជាមួយប្រជាពលរដ្ឋដែរ ដូចជាសេចក្តីសម្រេចធ្វើប្រតិភូកម្មបន្តជាដើម។ ក្នុងករណីដែល

សេចក្តីសម្រេចយកទៅប្រើប្រាស់ជាមួយពលរដ្ឋជាទូទៅ សិទ្ធិ និងកាតព្វកិច្ចមួយចំនួននឹងត្រូវផ្តល់ឲ្យពលរដ្ឋ ហើយវាអាចប្រែប្រួលទៅតាមប្រតិភូកម្មអំណាច និង ប្រតិភូកម្មហត្ថលេខាដែរ។

**ក- ចំពោះប្រតិភូកម្មអំណាច**

សេចក្តីសម្រេចរបស់អាជ្ញាធរដែលទទួលប្រតិភូកម្ម យកទៅប្រើប្រាស់ចំពោះពលរដ្ឋ មានតម្លៃត្រឹមតែជាសេចក្តីសម្រេចក្នុងឋានានុក្រមរបស់អាជ្ញាធរដែលទទួលប្រតិភូកម្មប៉ុណ្ណោះ។ ដូច្នេះហើយប្រជាពលរដ្ឋមានសិទ្ធិប្តឹងទាមទារការជួសជុលសំណងការខូចខាត រាល់សេចក្តីសម្រេចរបស់អាជ្ញាធរទទួលប្រតិភូកម្មដែលមានលក្ខណៈមិនស្របច្បាប់ ដោយពួកគាត់ត្រូវធ្វើពាក្យបណ្តឹងទៅតុលាការ ឬប្តឹងទៅប្រធានឋានានុក្រម (អាជ្ញាធរធ្វើប្រតិភូកម្ម) ដើម្បីកែប្រែសេចក្តីសម្រេចរបស់អាជ្ញាធរទទួលប្រតិភកម្មដែលមិនស្របច្បាប់នោះ។

**ខ- ចំពោះប្រតិភូកម្មហត្ថលេខា**

សេចក្តីសម្រេចរបស់អាជ្ញាធរទទួលប្រតិភកម្ម អាចយកទៅប្រើប្រាស់ជាមួយពលរដ្ឋមានតម្លៃដូចជាសេចក្តីសម្រេចក្នុងនាមរបស់អ្នកធ្វើប្រតិភូកម្ម។ ហេតុនេះហើយបានជាពេលមានបញ្ហាកើតឡើងទាក់ទងនឹងសេចក្តីសម្រេចរបស់អ្នកទទួលប្រតិភូកម្ម ដូចជាសេចក្តីសម្រេចមិនស្របច្បាប់ជាដើម វាធ្វើឲ្យមានការខូចខាតដល់ប្រយោជន៍ទូទៅ ប្រជាពលរដ្ឋអាចប្តឹងទាមទារការទទួលខុសត្រូវពីអ្នកធ្វើប្រតិភូកម្ម។

## កថាខណ្ឌ៤ ការបញ្ចប់ប្រតិភូកម្ម

គោលបំណងនៃប្រតិភូកម្ម ធ្វើឡើងដើម្បីសម្រួលក្នុងការអនុវត្តសេវាសាធារណៈ ឲ្យកាន់តែប្រសើរ និងរលូនឡើងថែមទៀតនោះ ដូច្នេះ ការកំណត់រយៈពេលប្រតិភូកម្មក្នុងនីតិរដ្ឋបាល វាដូចជាការកំណត់រយៈពេលចំពោះសេវាសាធារណៈដែរ ដូចនេះការកំណត់ថេរៈវេលាចំពោះសេវាសាធារណៈ មិនអាចធ្វើឡើងបានទេ ព្រោះវាប្រឆាំងនឹងគោលការណ៍និរន្តរភាពនៃសេវាសាធារណៈ។ ដោយហេតុនេះហើយ បានជាគេមិនអាចកំណត់វេលា ចំពោះប្រតិភូកម្មនៅក្នុងនីតិរដ្ឋបាលបាន ព្រោះការងារនៅក្នុងការបម្រើសេវាសាធារណៈវាអាចប្រែប្រួលមិនច្បាស់លាស់ ពេលខ្លះតម្រូវការសេវាកើនឡើង ភ្លាមៗធ្វើឲ្យការងារកើនឡើងនាំឲ្យរយៈពេលនៃការអនុវត្តមានរយៈពេលវែង ប្រតិភូកម្មក៏មានរយៈពេលវែងទៅតាមនោះដែរ ពេលខ្លះសេវាថយចុះនាំឲ្យការអនុវត្តមានរយៈពេលខ្លី ប្រតិភូកម្មក៏មានរយៈៈពេលខ្លីដែរ។ ទោះជាយ៉ាងនេះក្តី ក៏ប្រតិភូកម្មមិនអាច ធ្វើជា

រៀងរហូតបានដែរ គឺវាត្រូវតែបញ្ចប់ ដែលមានលក្ខណៈខុសគ្នារវាងប្រតិភូកម្មអំណាច និងប្រតិភូ-កម្មហត្ថលេខា។

### ក- ការបញ្ចប់ប្រតិភូកម្មអំណាច

ប្រតិភូកម្មអំណាច គឺជាការរំលែកសមត្ថកិច្ចពីស្ថាបន័មួយទៅស្ថាប័នមួយទៀត ដែលមានលក្ខណៈ អរូបិយមិនចំពោះបុគ្គលណាមួយទេ ។ ដូច្នេះវាមិនអាចត្រូវបានបញ្ចប់ដោយការផ្លាស់ប្តូរអ្នកទទួល ឬអ្នកធ្វើប្រតិភូកម្មនោះទេ តែវានឹងត្រូវបញ្ចប់ប្រសិនបើភារកិច្ចនោះត្រូវបានអាជ្ញាធរធ្វើប្រតិភូកម្មដកមកវិញដើម្បីអនុវត្តខ្លួនឯង ។

### ១- ការបញ្ចប់ប្រតិភូកម្មដោយមានលិខិតដកមកវិញ

ជាគោលការណ៍ប្រតិភូកម្មនឹងស្ថិតនៅរៀងរហូតប្រសិនបើគ្មានការដកមកវិញដោយអាជ្ញាធរធ្វើប្រតិភូកម្មទេ ទោះបីជាអាជ្ញាធរធ្វើប្រតិភូកម្ម ឬអាជ្ញាធរដែលទទួលប្រតិភូកម្មត្រូវផ្លាស់ប្តូរចេញក៏ដោយ ។ ដូច្នេះ ដើម្បីឲ្យអាជ្ញាធរធ្វើប្រតិភូកម្មអាចយកសមត្ថកិច្ចដែលបានធ្វើប្រតិភូកម្មមកអនុវត្តដោយផ្ទាល់ខ្លួនបានវិញ លុះត្រាតែគាត់ដកយកប្រតិភូកម្មអំណាចនោះមកវិញ តាមរយៈការចេញលិខិតដកមកវិញមួយដែលមានតម្លៃស្មើនឹងលិខិតធ្វើប្រតិភូកម្ម បានន័យថាទាំងការធ្វើនិងការដកមកវិញនូវប្រតិភូកម្ម គឺត្រូវគោរពទម្រង់ជាលាយលក្ខណ៍អក្សរដែលមានតម្លៃគតិយុត្តប៉ុនគ្នា ឬស្មើគ្នា ។ ការដកមកវិញនេះក៏ត្រូវតែផ្សព្វផ្សាយជាសាធារណៈដែរ ជាប្រយោជន៍ដល់ប្រជាពលរដ្ឋក្នុងការប្តឹងទាស់ចំពោះសេចក្តីសម្រេចក្រោយៗទៀត។ ការដកយកមកវិញ អាចបណ្តាលមកពីអាជ្ញាធរដែលទទួលប្រតិភូកម្មអនុវត្តសមត្ថកិច្ចដែលបានផ្ទេរមិនបានល្អ ឬប្រព្រឹត្តកំហុសក្នុងការអនុវត្តដូចជាការធ្វើហួសសមត្ថកិច្ចជាដើម ឬអាចបណ្តាលមកពីការងាររបស់អាជ្ញាធរធ្វើប្រតិភូកម្មលែងមមាញឹកដែលអាចឲ្យគាត់អនុវត្តបានវិញ នូវភារកិច្ចដែលបានផ្ទេរនោះដោយខ្លួនឯងវិញ។ ការអនុវត្តសមត្ថកិច្ចរបស់ខ្លួនដោយខ្លួនឯងវាប្រសើរជាងអ្នកដទៃអនុវត្តជំនួស ព្រោះថា អ្នកជំនួសអាចប្រព្រឹត្តកំហុសច្រើនដោយកង្វះបទពិសោធន៍ ឬ កង្វះសមត្ថភាពចំពោះការងារ ។ ក្នុងនោះដែរករណីអាជ្ញាធរដែលទទួលប្រតិភូកម្ម មិនអនុវត្តភារៈកិច្ចដែលខ្លួនទទួលបាន ក៏អាចជាមូលហេតុនៃការដកយកប្រតិភូកម្មមកវិញដែរ។

### ២- ការបញ្ចប់ប្រតិភូកម្មដោយការខារបានអនុវត្តន៍រួច (បញ្ចប់ដោយស្វ័យប្រវត្ត)

នៅក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួន ដើម្បីបម្រើសេវាសាធារណៈ ពេលខ្លះភ្នាក់ងាររដ្ឋបាលជួបប្រទះកំណើនការងារនៅក្នុងកំឡុងពេលមួយយ៉ាងខ្លី ហើយមិនអាចអនុវត្តដោយខ្លួនឯងផ្ទាល់

បានទាំងអស់ទេ ដូចនេះចាំបាច់ត្រូវផ្ទេរការងារនោះមួយចំនួន ទៅឲ្យភ្នាក់ងារថ្នាក់ក្រោមជួយធ្វើដោយផ្តល់សិទ្ធិ និងកាតព្វកិច្ចតាមរយៈប្រតិភូកម្មអំណាច។ ក្នុងករណីនេះប្រតិភូកម្មនេះនឹងត្រូវបញ្ចប់ដោយខ្លួនឯង ដោយមិនបាច់មានលិខិតដកមកវិញទេ នៅពេលការងារត្រូវបំពេញនោះលែងមានតទៅទៀត។ ឧទាហរណ៍ ប្រតិភូកម្មអំណាចដែលក្រសួងមហាផ្ទៃ ធ្វើទៅឲ្យអភិបាលខេត្ត ក្រុងតាមរយៈប្រកាសលេខ១២៦ប្រ.ក ចុះថ្ងៃទី ១៨ កុម្ភៈ ២០០២ ស្តីពីការធ្វើប្រតិភូកម្មអំណាចក្នុងការចាត់ចែងដំណើរការកិច្ចប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រតិភូកម្មនេះត្រូវបានបញ្ចប់នៅពេលដែលការប្រជុំប្រកាសសុពលភាពក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានរៀបចំរួចរាល់ ដោយពុំចាំបាច់ក្រសួងមហាផ្ទៃចេញសេចក្តីប្រកាសបញ្ចប់ប្រតិភូកម្មនេះឡើយ។ ហេតុដូច្នេះហើយបានជាគេហៅថា ការបញ្ចប់ប្រតិភូកម្មដោយស្វ័យប្រវត្តិ ។

### ខ- ការបញ្ចប់ប្រតិភូកម្មហត្ថលេខា

ការបញ្ចប់ប្រតិភូកម្មហត្ថលេខា ក៏ដូចជាការបញ្ចប់ប្រតិភូកម្មអំណាចដែរ គឺវាអាចត្រូវបញ្ចប់ដោយការងារដែលត្រូវបំពេញនោះបានអនុវត្តរួច។ ប៉ុន្តែ មានលក្ខណៈខុសគ្នាបន្តិចដោយប្រតិភូកម្មហត្ថលេខាត្រូវបញ្ចប់នៅពេលមានការផ្លាស់ប្តូរបុគ្គលធ្វើប្រតិភូកម្ម ឬ បុគ្គលដែលទទួលប្រតិភូកម្មដោយមូលហេតុផ្សេងៗ។ រីឯការដកមកវិញ វាជាការអនុវត្តសមត្ថកិច្ចនោះ រួមជាមួយនឹងប្រតិភូកម្មទៀតផង។

#### ១- ការបញ្ចប់ប្រតិភូកម្មហត្ថលេខាដោយការងារត្រូវបញ្ចប់

ប្រតិភូកម្មហត្ថលេខា គឺជាការផ្ទេរការចុះហត្ថលេខាទៅអោយបុគ្គលជាក់លាក់មួយរូបលើកិច្ចការរដ្ឋបាលអ្វីមួយ កិច្ចការដែលត្រូវផ្ទេរនោះ ពេលខ្លះមានវិសាលភាពក្នុងការអនុវត្តមានលក្ខណៈតូចចង្អៀតអាចបំពេញក្នុងរយៈពេលមួយខ្លីក៏ត្រូវបញ្ចប់។ ការបញ្ចប់ការងារផ្ទេរនេះគឺជាការបញ្ចប់ប្រតិភូកម្មហត្ថលេខាដែរ ព្រោះថាកម្មវត្ថុនៃប្រតិភូកម្មលែងមានទៀតហើយ។ លើសពីនេះទៀតប្រតិភូកម្មអាចបំពេញការងារដែលទាក់ទងនឹងសមត្ថកិច្ចបានធ្វើប្រតិភូកម្មពីមុននោះបានលុះត្រាតែមានប្រតិភូកម្មជាលាយលក្ខណ៍អក្សរសារជាថ្មីទោះជាការងារនោះដដែលក៏ដោយ។

#### ២-ការបញ្ចប់ប្រតិភូកម្មហត្ថលេខាដោយការផ្លាស់ប្តូរបុគ្គលដែលធ្វើប្រតិភូកម្ម ឬបុគ្គលដែលទទួលប្រតិភូកម្ម

ប្រតិភូកម្មហត្ថលេខានឹងត្រូវបញ្ចប់ដោយការផ្លាស់ប្តូរបុគ្គលដែលធ្វើប្រតិភូកម្ម ឬ បុគ្គលដែល

ទទួលប្រតិភូកម្ម ព្រោះវាធ្វើឡើងចំពោះបុគ្គលមានលក្ខណៈច្បាស់លាស់ មានន័យថា ប្រតិភូកម្មហត្ថលេខានឹងត្រូវបញ្ចប់ឥទ្ធិពលរបស់វាជាចាំបាច់ នៅពេលដែលបុគ្គលដែលធ្វើប្រតិភូកម្ម ឬ បុគ្គលដែលទទួលប្រតិភូកម្មឈប់កាន់តំណែងរបស់ខ្លួន។ ច្បាស់ជាងនេះទៅទៀត នឹងជាលក្ខណៈដើម្បីជៀសវៀងការប៉ះពាល់ដល់គោលការណ៍និរន្តរភាពនៃសេវាសាធារណៈ ប្រតិភូកម្មហត្ថលេខាបញ្ចប់នៅថ្ងៃដែលអ្នកជំនួសបុគ្គលដែលធ្វើប្រតិភូកម្ម ឬ បុគ្គលដែលទទួលប្រតិភូកម្មចូលកាន់តំណែង។ យុត្តិសាស្រ្តរបស់បារាំងក៏បានទទួលស្គាល់ផងដែរថា ការផ្តល់ប្រតិភូមួយទៅឲ្យមន្រ្តីរាជការមួយរូបដែលដូចគ្នាទៅនឹងប្រតិភូកម្មដែលបានផ្តល់ទៅឲ្យមន្រ្តីរាជការមួយរូបទៀតពីមុនមកនាំឲ្យបញ្ចប់ប្រតិភូកម្មដែលបានធ្វើមុននោះ ( សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋបារាំងចេញថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៨៧)។

# ជំពូកទី២

# ការអនុវត្តជាក់ស្តែងនៅកម្ពុជា

រវាងទ្រឹស្តី និងការអនុវត្តជាក់ស្តែងវិធាននៃប្រតិភូកម្មមិនដូចគ្នាទាំងស្រុងនោះទេ ទោះជាយ៉ាងណាក្តីគ្រប់រដ្ឋបាលទាំងអស់នៃប្រទេសនៅក្នុងសកលលោកសុទ្ធតែយកវិធាននេះមកអនុវត្តដើម្បីសម្រួលក្នុងការងាររដ្ឋបាលរបស់ខ្លួន។

តើការអនុវត្តជាក់ស្តែងនៅកម្ពុជាវាបានជួយសម្រួលអ្វីខ្លះក្នុងការងាររដ្ឋបាល និងវាមានផលវិបាកអ្វីខ្លះចំពោះរដ្ឋបាល?

## ផ្នែកទី១

## ប្រតិភូកម្មថ្នាក់ជាតិ

ប្រតិភូកម្មថ្នាក់ជាតិ គឺជាការធ្វើប្រតិភូកម្មរដ្ឋបាលថ្នាក់ជាតិៈ ព្រះមហាក្សត្រ នាយករដ្ឋមន្រ្តី រដ្ឋមន្រ្តី ឬរដ្ឋលេខាធិការដែលជាប្រធានស្ថាប័នស្វយ័ត។

### កថាខណ្ឌ១ ព្រះមហាក្សត្រ

ព្រះមហាក្សត្រជាប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា។ ប្រមុខរដ្ឋស្តីទីរបស់ព្រះអង្គអាចជាប្រធានព្រឹទ្ធសភា។ ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រក្នុងឋានៈជាព្រះរាជានុសិទ្ធិ ពេលព្រះអង្គប្រឈួនជាទម្ងន់ ប្រធានរដ្ឋសភាជាអ្នកបំពេញភារកិច្ចនេះ។

តំណែងជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រក្នុងឋានៈជាព្រះរាជានុសិទ្ធិ អាចនឹងផ្ទេរឥស្សរជនផ្សេងទៀត តាមឋានានុក្រមដូចតទៅ:

ក. អនុប្រធានទី ១ ព្រឹទ្ធសភា

ខ. អនុប្រធានទី ១ រដ្ឋសភា

គ. អនុប្រធានទី ២ ព្រឹទ្ធសភា

ឃ. អនុប្រធានទី ២ រដ្ឋសភា[៤]។

[៤] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, ២៤ កញ្ញា ១៩៩៣, មាត្រា១១ ថ្មី

ក្នុងករណីព្រះមហាក្សត្រព្រះអង្គប្រឈួន នោះប្រធានព្រឹទ្ធសភាបំពេញភារកិច្ចជាប្រមុខរដ្ឋជំនួសព្រះអង្គក្នុងឋានៈជាព្រះរាជានុសិទ្ធិ។ មាត្រា១១ ថ្មី នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានចែងថា "*ក្នុងករណីដែលព្រះមហាក្សត្រពុំអាចបំពេញព្រះរាជភារៈ ជាព្រះប្រមុខរដ្ឋបានដូចធម្មតាដោយព្រះអង្គប្រឈួនជាទម្ងន់ មានការបញ្ជាក់ដោយក្រុមគ្រូពេទ្យជំនាញជ្រើសរើសដោយប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នោះប្រធានព្រឹទ្ធសភាបំពេញភារកិច្ចប្រមុខរដ្ឋជំនួសព្រះអង្គក្នុងឋានៈជាព្រះរាជានុសិទ្ធិ*"។

ឧទាហរណ៍ នៅក្នុងព្រះរាជសារ ចុះថ្ងៃទី ១៨ កុម្ភៈ ឆ្នាំ២០១៤ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងមានព្រះរាជបន្ទូលឲ្យដឹងថា "*ព្រះអង្គអវត្តមានពីមាតុភូមិចាប់ពីថ្ងៃទី ១៩ កុម្ភៈ ឆ្នាំ២០១៤ តទៅនឹងធ្វើដំណើរទៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីពិនិត្យព្យាបាលព្រះរាជសុខភាព។*

*នៅក្នុងឱកាសអវត្តមានរបស់ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំខាងលើនេះ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នឹងទទួលជួយទូលព្រះបង្គំខ្ញុំ ក្នុងឋានៈជាប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា*"។

ម្យ៉ាងវិញទៀត ក្នុងករណីព្រះមហាក្សត្រប្រឈួន ហើយត្រូវព្យាបាលព្រះរោគនៅបរទេស ក្នុងពេលនោះព្រះមហាក្សត្រ មានសិទ្ធិផ្ទេរអំណាចឡាយព្រះហស្តលេខា នៅលើព្រះរាជក្រម ឬព្រះរាជក្រឹត្យខាងលើនេះទៅប្រមុខរដ្ឋស្តីទីចុះហត្ថលេខាជំនួសដោយព្រះរាជសារប្រគល់សិទ្ធិ[៥]។

យោងតាមខ្លឹមសារនៃបទបញ្ញត្តិនេះហើយ គេសង្កេតឃើញថា ក្រោយពីការបោះឆ្នោតរាជរដ្ឋាភិបាលនីតិកាលទី៣ ឆ្នាំ២០០៣ រួចមក កម្ពុជាបានជួបប្រទះនូវភាពរាំងស្ទះផ្នែកនយោបាយ ដូចនេះហើយ ដើម្បីទម្លុះទម្លាយវិបត្តិនយោបាយដែលបានជាប់គាំងជាច្រើនខែនោះ ច្បាប់ធម្មនុញ្ញបន្ថែមត្រូវបានបង្កើតឡើងសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ។ ប៉ុន្តែ ក្នុងពេលនោះ អង្គព្រះមហាក្សត្រ ព្រះបរមរតនកោដ្ឋ ព្រះករុណាសម្តេចព្រះ **នរោត្តម សីហនុ** ទ្រង់កំពុងគង់ប្រថាប់នៅឯបរទេស ហើយ សម្តេច ជា ស៊ីមដែលត្រូវបានគាំទ្រឲ្យធ្វើជាប្រធានព្រឹទ្ធសភាតាមរយៈពិធីសារនៃកិច្ចព្រមព្រៀងរវាងសហប្រតិបត្តិការរវាង គណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុន

[៥] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣,២៤ កញ្ញា១៩៩៣ មាត្រា២៨ថ្មី

ស៊ិនប៊ិច ក៏បានចាកចេញទៅក្រៅប្រទេសភ្លាមៗដោយមានការបញ្ជាក់ថា សម្តេចមានជម្ងឺ តួនាទីប្រមុខរដ្ឋស្តីទីត្រូវបំពេញដោយ ឯកឧត្តម ញឹក ប៊ុនឆៃ ដែលជាអនុប្រធានទី២ នៃព្រឹទ្ធសភា ដោយបានចុះហត្ថលេខាក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់ ក្នុងឋានៈជាប្រមុខរដ្ឋស្តីទី ។

បន្ថែមពីលើនេះទៀត មាត្រា ១២ថ្មី នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានចែងថា " *នៅពេលព្រះមហាក្សត្រចូលទីវង្គត ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ក្នុងឋានៈជាព្រះរាជានុសិទ្ធិ នៃរដ្ឋព្រះរាជាណាចក្រកម្ពុជា។*

*ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រ ក្នុងពេលព្រះអង្គចូលទីវង្គត ការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីក្នុងឋានៈជាព្រះរាជានុ-សិទ្ធិត្រូវអនុវត្តតាមវាក្យខណ្ឌទី ២ និងទី ៣ នៃមាត្រា ១១ថ្មី"។*

ឧទាហរណ៍ ដើម្បីសម្គាល់ពីការចុះហត្ថលេខាលើព្រះរាជក្រឹត្យទាក់ទងទៅនឹងស្តីទីព្រះមហាក្សត្រនៅលើព្រះរាជក្រឹត្យមានលក្ខណៈពិសេសដូចគំរូខាងក្រោមៈ

រាជធានីភ្នំពេញ, ថ្ងៃទី...ខែ...ឆ្នាំ...

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ញឹក ប៊ុនឆៃ**

រាល់ខ្លឹមសារនៃបទបញ្ញត្តិច្បាប់ដែលបានរៀបរាប់ខាងលើនេះ សបង្ហាញឲ្យឃើញពីប្រតិភូកម្មរបស់ព្រះមហាក្សត្រ ដែលបានកំណត់យ៉ាងជាក់លាក់នៅក្នុងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ប្រទេស។

### កថាខណ្ឌ ២ នាយករដ្ឋមន្ត្រី

នាយករដ្ឋមន្ត្រី ជាប្រមុខរដ្ឋាភិបាលមានភារៈទទួលខុសត្រូវរួមជាមួយសមាជិកទាំងឡាយនៃ

រាជរដ្ឋាភិបាលចំពោះមុខរដ្ឋសភា អំពីនយោបាយទូទៅ និងសកម្មភាពរបស់រដ្ឋាភិបាល[៦]។

នាយករដ្ឋមន្ត្រីអាចចែករំលែកអំណាចរបស់ខ្លួនឱ្យទៅឧបនាយករដ្ឋមន្ត្រី ឬសមាជិកណាមួយនៃរាជរដ្ឋាភិបាលបាន។ ក្នុងពេលដែលនាយករដ្ឋមន្ត្រីអវត្តមាន ឧបនាយករដ្ឋមន្ត្រីទទួលការងារតាមការប្រគល់សិទ្ធិចំពោះមុខពីនាយករដ្ឋមន្ត្រី[៧]។ ឧទាហរណ៍ សេចក្ដីសម្រេចលេខ ០២សសរ របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥ បានផ្ទេរសិទ្ធិជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃជានាយករដ្ឋមន្ត្រីស្ដីទីនៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្ដេចអគ្គមហាសេនាបតី **ហ៊ុន សែន** ដែលត្រូវអញ្ជើញទៅចូលរួមកិច្ចប្រជុំឆ្នាំ២០១៥ នៃវេទិកាសេដ្ឋកិច្ចពិភពលោកលើកទី ៤៥ចាប់ពីថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៥ នៅទីក្រុង Davos-Klosters ប្រទេសស្វីស រហូតដល់ពេលសម្ដេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ។

បន្ថែមពីនេះទៀត មាត្រា ១២ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ បានចែងថា " *នាយករដ្ឋមន្ត្រីដឹកនាំការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម សហប្រតិបត្តិការ សេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស និងការពារប្រទេស។ នាយករដ្ឋមន្ត្រី អាចប្រគល់សិទ្ធិឲ្យសមាជិករាជរដ្ឋាភិបាលណាម្នាក់ជាអ្នកចរចា និងជាអ្នកចុះហត្ថលេខា* "។

ឧទាហរណ៍ លិខិតសិទ្ធិប្រទានលេខ ៥៥ របស់រាជរដ្ឋាភិបាលកម្ពុជាដែលបានចុះក្នុងរាជកិច្ចសប្ដាហ៍ទី១ ថ្ងៃទី០៤ កុម្ភៈ ឆ្នាំ ២០០៩ បានសម្រេចប្រគល់សិទ្ធិពេញសមត្ថភាព ជូនឯកឧត្តម គាត ឈន់ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងអនុវត្តគម្រោង IMPLEMENTATION AGREEMENT (IA) លើកិច្ចព្រមព្រៀងជួល LEASE AGREEMENT (LA) និងលើលិខិតធានាទូទាត់ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា GOVERNMENT GUARANTEE OF PAYMENT ដោយក្រុមហ៊ុនអគ្គិសនីកម្ពុជា (EDC) ទៅឱ្យក្រុមហ៊ុន MICHELLE CORPORATION សម្រាប់គម្រោងវិនិយោគ វារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម កម្លាំង ៣៣៨ មេហ្គាវ៉ាត់នៅខេត្តកោះកុង។

ទន្ទឹមនឹងនេះរាជរដ្ឋាភិបាលក៏បានធ្វើប្រតិភូកម្មដល់រដ្ឋមន្ត្រីនៃក្រសួងនីមួយៗផងដែរ ដើម្បីអនុវត្តបេសកកម្មរបស់ខ្លួន។ តាមគោលការណ៍ រដ្ឋមន្ត្រីមិនមានអំណាចចេញបទបញ្ជាទេ ប៉ុន្តែ ក្នុង

---

[៦] ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ២០ កក្កដា ១៩៩៤, មាត្រា៨

[៧] ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ២០ កក្កដា ១៩៩៤, មាត្រា១៨

ករណីនាយករដ្ឋមន្ត្រីផ្ទេរទៅឲ្យខ្លួននូវអំណាចនេះ តាមរយៈអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅនៃក្រសួង រដ្ឋមន្ត្រីក៏អាចចេញបទបញ្ញាបានដែរ។

ឧទាហរណ៍ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់បេសកកម្មឲ្យដឹកនាំ និងគ្រប់គ្រងការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែតំបន់ណា ឬសមត្ថកិច្ចណា ដែលរាជរដ្ឋាភិ-បាលប្រគល់ឲ្យស្ថាប័នមួយផ្សេងទៀត[៨]។

នាយករដ្ឋមន្ត្រី តាមរយៈច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ក៏អាចផ្ទេរអំណាចរបស់ខ្លួនខាងផ្នែកហិរញ្ញវត្ថុទៅឲ្យរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ក្នុងការចុះហត្ថលេខានៃកិច្ចព្រមព្រៀងកម្ចីជាមួយមូលនិធិរូបិយវត្ថុពិភពលោកដើម្បីបំពេញនូវឱនភាពថវិកា។

ចំពោះរដ្ឋបាលខេត្ត ក្រុងវិញ អនុក្រឹត្យលេខ ២៩ ស្តីពីសមត្ថកិច្ចខេត្ត ក្រុង ឆ្នាំ១៩៩៩ បានបង្ហាញឲ្យឃើញពីការធ្វើប្រតិភូកម្មសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលទៅឲ្យរដ្ឋបាលខេត្ត ក្រុង។ តាមរយៈប្រតិភូកម្មនេះខេត្ត ក្រុង ទទួលបាននូវសមត្ថកិច្ចធំៗបួនរួមមាន៖

- សមត្ថកិច្ចស្តីពីការរៀបចំផែនការ និងកម្មវិធីអភិវឌ្ឍន៍
- សមត្ថកិច្ចស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- សមត្ថកិច្ចស្តីពីការងារសាធារណការ
- សមត្ថកិច្ចស្តីពីសេវាសាធារណៈ[៩]។

## កថាខណ្ឌ៣ រដ្ឋមន្ត្រី

រដ្ឋមន្ត្រី ជាប្រធានស្ថាប័ន។ ក្នុងឋានៈនេះរដ្ឋមន្ត្រីមានអំណាចឋានានុក្រម ទាំងទៅលើសេវា និងបុគ្គលិកក្រោមឱវាទរបស់ខ្លួន។ដើម្បីជួយសម្រួលកុំឲ្យកំណើនការងារមានការកើនឡើងរដ្ឋមន្ត្រីអាចធ្វើប្រតិភូកម្មទៅឲ្យសហការីរបស់ខ្លួនតាមរយៈប្រកាស ឧទាហរណ៍ ប្រកាសលេខ៦២២ សហវ.ប្រក ចុះថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ ២០១៦ ស្តីពី ការបែងចែកភារកិច្ចរបស់អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកំណត់ភារកិច្ចតាមក្របខណ្ឌការងារជូនអនុរដ្ឋលេខាធិការឲ្យ

[៨] អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៦២អនក្រ/បក, ២០ កក្កដា ១៩៩៩, មាត្រា២

[៩] អនុក្រឹត្យស្តីពី សមត្ថកិច្ចខេត្ត ក្រុង, លេខ២៩អនក្រ.បក, ០៩ មេសា ១៩៩៩, មាត្រា ២

ទទួលបន្ទុកការងាររៀងៗខ្លួន។ អនុរដ្ឋលេខាធិការ អាចជួយទេសរដ្ឋមន្ត្រី ក្នុងការបំពេញកិច្ចការផ្សេងៗ ទៅតាមការប្រគល់សិទ្ធិរបស់ទេសរដ្ឋមន្ត្រី[១០]។

ម្យ៉ាងវិញទៀត ដើម្បីជំរុញឲ្យការបំពេញការងារនៅតាមមូលដ្ឋានបានចំគោលដៅ និងងាយស្រួល ដល់ប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាសាធារណៈ ក្រសួងនីមួយៗបានធ្វើប្រតិភូកម្ម ក៏ដូចជាធ្វើវិមជ្ឈការអំណាចទៅថ្នាក់មូលដ្ឋាន ដើម្បីឲ្យអាជ្ញាធរថ្នាក់មូលដ្ឋានមានសមត្ថកិច្ចគ្រប់គ្រាន់ក្នុងការបំពេញតួនាទីរបស់ខ្លួន។ ខាងក្រោមនេះជាលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដែលបង្ហាញពីការធ្វើប្រតិភូកម្មពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ នៃក្រសួងមហាផ្ទៃ។

**ប្រកាសលេខ ១៨៨៤ ប្រក .របស់ក្រសួងមហាផ្ទៃ** ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០២ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុងក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ២០០២ ក្រសួងមហាផ្ទៃបានសម្រេចធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ក្នុងនាមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីសម្របសម្រួលការអនុវត្តន៍ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ និងការអនុវត្តគោលនយោបាយវិមជ្ឈការនៅតាមខេត្តក្រុងនីមួយៗ ពោល អភិបាលខេត្តក្រុងគឺជាច្រកផ្លូវនៃការទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងខេត្ត ក្រុងរបស់ខ្លួនជាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន ឬភ្នាក់ងាររបស់រាជរដ្ឋាភិបាល ព្រមទាំងអង្គការជាតិ និងអង្គការអន្តរជាតិនានា។

**ប្រកាសលេខ ២៤០៩ ប្រក. របស់ក្រសួងមហាផ្ទៃ** ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្តក្នុងការផ្ទៀងផ្ទាត់លក្ខខណ្ឌនានា នៃសំណើសុំផ្ទេរមូលនិធិក្រុង ស្រុក ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានប្រតិភូកម្មអំណាចដល់អភិបាលរាជធានីខេត្ត ក្នុងការផ្ទៀងផ្ទាត់លក្ខខណ្ឌនានានៃសំណើសុំផ្ទេរមូលនិធិក្រុង ស្រុកសម្រាប់ត្រីមាសទី២ ទី៣ និងទី៤នៃឆ្នាំនីមួយៗរបស់រដ្ឋបាលក្រុង ស្រុកដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខេត្តសាមី ដើម្បីបញ្ជូនសំណើសុំផ្ទេរមូលនិធិក្រុង ស្រុក មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[១១] ។

**ប្រកាសលេខ៨៤៦ប្រក** ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៧ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាល ក្នុងដំណើរការកិច្ចប្រជុំលើកទីមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី

---

[១០] ប្រកាស ស្តីពីការបែងចែកភារកិច្ចរបស់អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,លេខ ៦២២ សហវ ប្រក,៣១ ឧសភា ២០១៦, ប្រការ២

[១១] ប្រកាស ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្នុងការផ្ទៀងផ្ទាត់លក្ខខណ្ឌនានានៃសំណើសុំផ្ទេរមូលនិធិក្រុងស្រុក, លេខ២៤០៩ប្រក,០៩ កក្កដា ២០១៣, ប្រការ១

នៃក្រសួងមហាផ្ទៃបានសម្រេចធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុងឲ្យទទួលខុសត្រូវអំពីដំណើរការចាត់ចែងការប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីស្ថិតក្នុងខេត្ត ក្រុងរបស់ខ្លួន។

ទន្ទឹមនឹងនេះដែរ ប្រកាសលេខ១៩១១ សហវប្រក ស្តីពីការដាក់ឲ្យអនុវត្តគោលការណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចែងថា រដ្ឋមន្ត្រីជាអាណាប័កដើមខ្សែ មានសិទ្ធិពេញលេញក្នុងការបញ្ជាប្រតិបត្តិចំណូល និងចំណាយថវិកាដោយខ្លួនឯងផ្ទាល់ ដោយត្រូវគោរពទៅតាមព្រំដែននៃសិទ្ធិអំណាច និងមុខងាររបស់ខ្លួន ។ មាត្រា៦៣ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨បានចែងថា " *រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែលដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន អាចប្រគល់សិទ្ធិជូនអភិបាលរដ្ឋបាលថ្នាក់ក្រោមជាតិ ជាអាណាប័កផ្ទេរសិទ្ធិសម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកាក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួន។ រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន អាចប្រគល់សិទ្ធិជូនប្រធានអង្គភាពក្រោមឱវាទ ប្រធានមន្ទីរជំនាញរាជធានី ខេត្តជាអាណាប័កផ្ទេរសិទ្ធិសម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកា បន្ទាប់ពីមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ* "។ ដោយផ្អែកលើក្របខណ្ឌគតិយុត្តនេះ ប្រធានមន្ទីរជំនាញរាជធានី ខេត្តនៃក្រសួងស្ថាប័នអនុវត្តថវិកាកម្មវិធីត្រូវបានទទួលការប្រទានសិទ្ធិពីរដ្ឋមន្ត្រី ប្រធានស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល ដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួនសម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកាកម្មវិធីរបស់ខ្លួន។

ក្រៅពីក្រសួងមហាផ្ទៃ ក៏នៅមានក្រសួងជាច្រើនទៀតដែលបានធ្វើប្រតិភូកម្មទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងទាំងនោះមានជាអាទ៍ ក្រសួងពាណិជ្ជកម្ម ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងសុខាភិបាល ក្រសួងទេសចរណ៍ ក្រសួងកសិកម្ម ក្រសួងអភិវឌ្ឍជនបទជាដើម ដែលការធ្វើប្រតិភូកម្មនេះធ្វើឡើងតាមប្រកាសនៃក្រសួងនីមួយៗដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ។

# ផ្នែកទី២

# ប្រតិភូកម្មថ្នាក់ក្រោមជាតិ

ដើម្បីឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានអំណាច ឬមានសមត្ថកិច្ចក្នុងការបំពេញមុខងាររបស់ខ្លួន អាចអនុវត្តតួនាទី និងភារកិច្ចថ្មី ដោយមានប្រសិទ្ធភាព និងស្របតាមលក្ខខណ្ឌគតិយុត្តដែលបានកំណត់ រដ្ឋបាលថ្នាក់ជាតិ ឬថ្នាក់កណ្ដាល ចាំបាច់ត្រូវធ្វើប្រតិភូកម្មរបស់ខ្លួនទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬថ្នាក់មូលដ្ឋានដើម្បីជួយសម្រួលការងារឲ្យសម្រេចបានឆាប់រហ័ស និងបង្វិតរដ្ឋបាលឲ្យកាន់តែកៀកជាមួយប្រជាពលរដ្ឋ ពោលសំដៅធានាដល់ការឆ្លើយតបទៅនឹងតម្រូវការ និងដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានឡើងនៅតាមមូលដ្ឋានឲ្យបានទាន់ពេលវេលា។

## កថាខណ្ឌ១ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

គ្រប់រាជធានី ខេត្តទាំងអស់ត្រូវរៀបចំឲ្យមានគណៈអភិបាលសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ[១២] ។ សមាសភាពរបស់គណៈអភិបាលរួមមានប្រធានមួយរូប ដែលហៅថាអភិបាល និងអភិបាលរងមួយចំនួន ពោលមានសមាសភាពពីបី ទៅប្រាំពីររូប ។

អភិបាលរាជធានី ខេត្ត ស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់ក្រសួងមហាផ្ទៃ និងជាតំណាងឲ្យគ្រប់រដ្ឋមន្ត្រីនៃក្រសួង ស្ថាប័ន នៅថ្នាក់កណ្ដាល។

អភិបាលរាជធានី ខេត្តមានតួនាទីទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល អំពីកិច្ចការទូទៅដែលកើតមាននៅក្នុងរាជធានី ខេត្តរបស់ខ្លួន និងជាអ្នកធានារ៉ាប់រងមិនឲ្យមានការបែងចែកទឹកដី រក្សាសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈធានាឲ្យមានការអនុវត្តច្បាប់ ជាពិសេសជាតួអង្គដ៏សំខាន់ដែលទទួលប្រតិភូកម្មពីក្រសួងមហាផ្ទៃដើម្បីមានសមត្ថ-កិច្ច និងអំណាចគ្រប់គ្រាន់ក្នុងការគ្រប់គ្រងក៏ដូចជាបំពេញតួនាទី និងមុខងាររបស់ខ្លួន។

### ក- អភិបាលនៃគណៈអភិបាលរាជធានី

#### ១- ប្រតិភូកម្មនៅក្នុងរបៀបរបបការងាររបស់គណៈអភិបាលរាជធានី

រាជធានី ត្រូវមានគណៈអភិបាលរាជធានី ដែលរួមមានអភិបាលរាជធានី និងអភិបាលរងរាជ-

[១២] ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ២៦ ឧសភា ២០០៨, មាត្រា១៣៨

ធានីមួយចំនួន ដែលត្រូវបានតែងតាំងឡើងស្របតាមលក្ខខណ្ឌនៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ[១៣] និងមានសមាជិកពីបី ទៅប្រាំពីររូប ដែលមានអភិបាលរាជធានីជាប្រធាននៃគណៈអភិបាល។

ទាក់ទិននឹងការធ្វើប្រតិភូកម្ម អភិបាលរាជធានី អាចប្រគល់សិទ្ធិដល់អភិបាលរង នៅក្នុងការចុះហត្ថលេខាលើឯកសារ លិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួន នៅក្នុងក្របខណ្ឌនៃភារកិច្ច ដែលបានបែងចែកជូនអភិបាលរងនីមួយៗ។ ប៉ុន្តែ អភិបាលរាជធានី ត្រូវទទួលខុសត្រូវ អំពីភាពត្រឹមត្រូវតាមបែបបទ និងនីតិវិធី ចំពោះឯកសារ លិខិតស្នាម ដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងរាជធានីទាំងនោះ និងមានសិទ្ធិដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងណាមួយ ដែលប្រើប្រាស់អំណាចនេះ មិនស្របច្បាប់ មិនស្របតាមបែបបទ និងនីតិវិធី[១៤]។

ម្យ៉ាងវិញទៀត ក្នុងករណីអភិបាលរាជធានីអវត្តមាន អភិបាលរាជធានី ត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ ជូនអភិបាលរងរាជធានីមួយរូប ឲ្យទទួលជាអភិបាលរាជធានីស្តីទី។ ប្រសិនបើអភិបាលរាជធានី អវត្តមានដោយពុំបានផ្ទេរសិទ្ធិ អភិបាលរងរាជធានី ដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃអនុក្រឹត្យតែងតាំងអភិបាលរងនៃគណៈអភិបាលរាជធានី ត្រូវធ្វើជាអភិបាលរាជធានីស្តីទី។ ក្នុងករណីដែលអភិបាលរាជធានីស្តីទីអវត្តមាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញប្រកាសដើម្បីប្រគល់ភារកិច្ចដល់អភិបាលរងរាជធានីមួយរូបឲ្យទទួលជាអភិបាលរាជធានីស្តីទី ហើយអភិបាលស្តីទីត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្តជូនអភិបាលរាជធានី នៅពេលដែលអភិបាលរាជធានីមានវត្តមានវិញ។ គណៈអភិបាលរាជធានី ឬអភិបាលរាជធានី ឬអភិបាលរងរាជធានីដែលបានសម្រេច ឬដែលបានអនុវត្តកិច្ចការណាមួយ ផ្ទុយនឹងច្បាប់លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណា ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សារាជធានី ការសម្រេច ឬសកម្មភាពនោះពុំមានសុពលភាពឡើយ។ គណៈអភិបាលរាជធានី ឬអភិបាលរាជធានី ឬអភិបាលរងរាជធានី ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីការសម្រេច ឬ

[១៣] អនុក្រឹត្យស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ, លេខ២១៥អនក្រ.បក, ១៨ ធ្នូ ២០០៩,មាត្រា២៥

[១៤] អនុក្រឹត្យស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ, លេខ២១៥អនក្រ.បក, ១៨ ធ្នូ ២០០៩,មាត្រា៣៨

សកម្មភាពទាំងនេះ។

### ២- ប្រតិភូកម្មនៅក្នុងទំនាក់ទំនងរវាងរដ្ឋបាលរាជធានីជាមួយរដ្ឋបាលខណ្ឌ

ទន្ទឹមនឹងនេះដែរ នៅក្នុងទំនាក់ទំនងរវាងរដ្ឋបាលរាជធានី និងរដ្ឋបាលខណ្ឌ ក៏មានលេចចេញនូវការធ្វើប្រតិភូកម្មផងដែរ ព្រោះថា ក្រុមប្រឹក្សាខណ្ឌត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សារាជធានីត្រូវធានាធ្វើប្រតិភូកម្មនូវមុខងារ និងភារកិច្ចសមស្របដល់ក្រុមប្រឹក្សាខណ្ឌ[១៥] ដើម្បីឲ្យក្រុមប្រឹក្សាខណ្ឌនីមួយៗលើកកម្ពស់ការចូលរួម និងភាពជាម្ចាស់របស់ប្រជាពលរដ្ឋសំដៅបង្កើត ជំរុញ និងធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ។ ដើម្បីធ្វើប្រតិភូកម្មមុខងារ ភារកិច្ចដល់ក្រុមប្រឹក្សាខណ្ឌក្រុមប្រឹក្សារាជធានី ត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ដែលពាក់ព័ន្ធ ដើម្បីរួមគ្នាពិចារណាអំពីភាពសមហេតុផលក្នុងការធ្វើប្រតិភូកម្មមុខងារ និងភាកិច្ចសមស្របទៅឲ្យក្រុមប្រឹក្សាខណ្ឌ ឬក្រុមប្រឹក្សាសង្កាត់ក្នុងការអនុវត្តមុខងារ និងភារកិច្ចទាំងនេះ។ ក្រុមប្រឹក្សារាជធានី ត្រូវធានាផ្តល់មធ្យោបាយសម្ភារៈ ធនធាននានារួមទាំងធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងការបណ្តុះបណ្តាល ការកសាងសមត្ថភាពក្រុមប្រឹក្សាខណ្ឌ និងបុគ្គលិករបស់ក្រុមប្រឹក្សាខណ្ឌ ដើម្បីអនុវត្តមុខងារ និងភារកិច្ចដែលក្រុមប្រឹក្សារាជធានីបានធ្វើប្រតិភូកម្មឲ្យ ហើយត្រូវធ្វើការត្រួតពិនិត្យនីត្យានុកូលភាពនៃការអនុវត្តមុខងារ និងភារកិច្ចដែលបានធ្វើប្រតិភូកម្មឲ្យក្រុមប្រឹក្សាខណ្ឌដើម្បីធានាថាក្រុមប្រឹក្សាខណ្ឌអនុវត្តមុខងារ និងភារកិច្ចទាំងនោះនៅក្នុងក្របខណ្ឌនៃការងារ ដែលបានធ្វើប្រតិភូកម្មឲ្យលើមូលដ្ឋាននៃការគោរពរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងធានាថា អាជ្ញាធរខណ្ឌឆ្លើយតបបានយ៉ាងប្រសើរបំផុតនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ[១៦]។

### ៣- ប្រតិភូកម្មនៅក្នុងទំនាក់ទំនងរវាងរដ្ឋបាលរាជធានីជាមួយរដ្ឋបាលសង្កាត់

នៅក្នុងអនុក្រឹត្យលេខ ២១៥ស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាគណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ ចុះថ្ងៃ១៤ ធ្នូ

[១៥] អនុក្រឹត្យស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ, លេខ២១៥អនក្រ.បក, ១៤ ធ្នូ ២០០៩,មាត្រា១១៨

[១៦] អនុក្រឹត្យស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ, លេខ២១៥អនក្រ.បក, ១៤ ធ្នូ ២០០៩,មាត្រា១២២

២០០៩ ក្រុមប្រឹក្សាសង្កាត់ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សារាជ-ធានី ដូចនេះក្រុមប្រឹក្សារាជធានីត្រូវធានាធ្វើប្រតិភូកម្មនូវមុខងារ និងភារកិច្ចសមស្របដល់ក្រុមប្រឹក្សាសង្កាត់ក្នុងរាជធានីរបស់ខ្លួន ដើម្បីធានាឲ្យក្រុមប្រឹក្សាសង្កាត់នីមួយៗមានលទ្ធភាពកាន់តែច្រើនថែមទៀត នៅក្នុងការបង្កើតការជំរុញ និងធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅតាមសង្កាត់នីមួយៗ។ មុខងារ និងភារកិច្ចដែលក្រុមប្រឹក្សារាជធានី ត្រូវធ្វើប្រតិភូកម្មដល់ក្រុមប្រឹក្សាសង្កាត់ គឺជាមុខងារ ភារកិច្ចដែលពាក់ព័ន្ធដោយផ្ទាល់ដល់ការផ្តល់ សេវាកម្ម ការអភិវឌ្ឍ និងសេចក្តីត្រូវការនៃជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ហើយក្រុមប្រឹក្សារាជធានី ត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ដែលពាក់ព័ន្ធ ដើម្បីរួមគ្នាពិចារណាអំពីភាពសមហេតុផលក្នុងការធ្វើប្រតិភូកម្មមុខងារ និងភាកិច្ចសមស្របទៅឲ្យក្រុមប្រឹក្សាខណ្ឌ ឬក្រុមប្រឹក្សាសង្កាត់ក្នុងការអនុវត្តមុខងារ និងភារកិច្ចទាំងនេះ។ ក្រុមប្រឹក្សារាជធានី ត្រូវធានាផ្តល់មធ្យោបាយ សម្ភារៈ ធនធាននានារួមទាំងធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងការបណ្តុះ-បណ្តាល ការកសាងសមត្ថភាពក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិករបស់ក្រុមប្រឹក្សាសង្កាត់ ដើម្បីអនុវត្តមុខងារ និងភារកិច្ចដែលក្រុមប្រឹក្សារាជធានីបានធ្វើប្រតិភូកម្មឲ្យ។

### ខ- អភិបាលនៃគណៈអភិបាលខេត្ត

#### ១ ប្រតិភូកម្មនៅក្នុងរបៀបរបបការងាររបស់គណៈអភិបាលខេត្ត

ខេត្ត នីមួយៗត្រូវមានគណៈអភិបាលខេត្តមួយ ដែលរួមមានអភិបាលខេត្ត និងអភិបាលរងខេត្តមួយចំនួនដែលត្រូវបានតែងតាំងឡើង ស្របតាមលក្ខខណ្ឌនៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ[១៧]។

ទាក់ទិននឹងការធ្វើប្រតិភូកម្ម អភិបាលខេត្ត អាចប្រគល់សិទ្ធិដល់អភិបាលរង នៅក្នុងការចុះហត្ថលេខាលើឯកសារ លិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួន នៅក្នុងក្របខណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងនីមួយៗ។ ប៉ុន្តែ អភិបាលខេត្ត ត្រូវទទួលខុសត្រូវ អំពីភាពត្រឹមត្រូវតាមបែបបទ និងនីតិវិធី ចំពោះឯកសារ លិខិតស្នាម ដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងរាជធានីទាំងនោះ និងមានសិទ្ធិដកហូតមកវិញ នូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងណាមួយដែលប្រើ

[១៧] អនុក្រឹត្យស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦អនក្រ.បក, ១៤ ធ្នូ ២០០៩,មាត្រា២៥

ប្រាស់អំណាចនេះ មិនស្របច្បាប់ មិនស្របតាមបែបបទ និងនីតិវិធី[១៨]។

ម្យ៉ាងវិញទៀត ក្នុងករណីអភិបាលខេត្តអវត្តមាន អភិបាលខេត្ត ត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអភិបាលរងខេត្តមួយរូបឲ្យទទួលជាអភិបាលខេត្តស្ដីទី។ ប្រសិនបើ អភិបាលខេត្តអវត្តមានដោយពុំបានផ្ទេរសិទ្ធិ អភិបាលរងខេត្ត ដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃអនុក្រឹត្យតែងតាំងអភិបាលរងនៃគណៈអភិបាលខេត្ត ត្រូវធ្វើជាអភិបាលខេត្តស្ដីទី។ ក្នុងករណីដែលអភិបាលខេត្តស្ដីទីអវត្តមាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញប្រកាស ដើម្បីប្រគល់ភារកិច្ចដល់អភិបាលរងខេត្តមួយរូបឲ្យទទួលជាអភិបាលខេត្តស្ដីទី ហើយអភិបាលស្ដីទីត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្តជូនអភិបាលខេត្ត នៅពេលដែលអភិបាលខេត្តមានវត្តមានវិញ។ គណៈអភិបាលខេត្ត ឬអភិបាលខេត្ត ឬអភិបាលរងខេត្តដែលបានសម្រេច ឬដែលបានអនុវត្តកិច្ចការណាមួយ ផ្ទុយនឹងច្បាប់លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណា ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាខេត្ត ការសម្រេច ឬសកម្មភាពនោះ ពុំមានសុពលភាពឡើយ។ គណៈអភិបាលខេត្ត ឬអភិបាលខេត្ត ឬអភិបាលរងខេត្តត្រូវទទួលខុសត្រូវ ចំពោះមុខច្បាប់អំពីការសម្រេច ឬសកម្មភាពទាំងនេះ។

### ២-ប្រតិភូកម្មនៅក្នុងទំនាក់ទំនងរវាងរដ្ឋបាលខេត្ត ជាមួយរដ្ឋបាលក្រុង ស្រុក ឃុំ និងសង្កាត់

ទន្ទឹមនឹងនេះដែរនៅក្នុងទំនាក់ទំនងរវាងរដ្ឋបាលខេត្ត ជាមួយរដ្ឋបាលក្រុងស្រុក ឃុំ និងសង្កាត់ ក៏មានលេចចេញនូវការធ្វើប្រតិភូកម្មដែរ ដោយក្រុមប្រឹក្សាខេត្តត្រូវបានទទួលការធ្វើប្រតិភូកម្មអំណាចក្នុងនាមរាជរដ្ឋាភិបាល ដើម្បីផ្ដល់ការគាំទ្រ និងការត្រួតពិនិត្យនីត្យានុកូលភាពលើសេចក្ដីសម្រេច និងសកម្មភាពរបស់រដ្ឋបាលក្រុង រដ្ឋបាលស្រុករដ្ឋបាលសង្កាត់ និងរដ្ឋបាលឃុំបំពេញមុខងារ និងភារកិច្ចដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្មស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងស្របតាមគោលនយោបាយរបស់ជាតិ។ ការធ្វើប្រតិភូកម្មនេះរួមមានៈ

- ការវាយតម្លៃ និងការរៀបចំយុទ្ធសាស្ត្រសមស្រប សម្រាប់ផ្ដល់ការគាទ្រខាងសមត្ថភាព ដល់ក្រុមប្រឹក្សាក្រុងក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាសង្កាត់ និងក្រុមប្រឹក្សាឃុំ ព្រមទាំងមន្ត្រីបុគ្គលិកនៃក្រុមប្រឹក្សាទាំងនេះ

[18] អនុក្រឹត្យស្ដីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦អនក្រ.បក, ១៤ ធ្នូ ២០០៩,មាត្រា៣៤

–ការណែនាំ និងសម្របសម្រួល គាំទ្រដល់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងការអនុវត្តមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ឲ្យស្របទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងគោលនយោបាយរបស់ជាតិ

–ត្រូវធានាថា ក្រុង ស្រុក បានធ្វើការគាំទ្រយ៉ាងត្រឹមត្រូវដល់សង្កាត់ក្នុងស្រុក និងឃុំ សង្កាត់ក្នុងស្រុក។

ពេលក្រុមប្រឹក្សាខេត្ត ត្រូវបានទទួលប្រតិភូកម្មពីរាជរដ្ឋាភិបាល ដើម្បីផ្តល់ការគាំទ្រ ការសម្របសម្រួល និងការធ្វើសហប្រតិបត្តិការជាមួយរដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ដើម្បីរួមគ្នាសម្រេចឲ្យបាននូវគោលនយោបាយជាតិ ក្រុមប្រឹក្សាខេត្តត្រូវធានាថា រដ្ឋបាល ស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់នៅក្នុងខេត្ត បំពេញមុខងារ និងភារកិច្ចដែលបានប្រគល់ឬបានធ្វើប្រតិភូកម្មឲ្យស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងគោលនយោបាយរបស់ជាតិ។

## កថាខណ្ឌ ២ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

ក្រុង ស្រុក ខណ្ឌនីមួយៗត្រូវមានគណៈអភិបាលមួយ ដែលរួមមាន អភិបាល អភិបាលរងមួយចំនួន ដែលត្រូវបានតែងតាំងឡើងស្របតាមលក្ខខណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជ-ធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

### ក-អភិបាលនៃគណៈអភិបាលក្រុង

ក្រុងនីមួយៗត្រូវមានគណៈអភិបាលក្រុងមួយដែលរួមមាន អភិបាលក្រុង និងអភិបាលរងក្រុងមួយចំនួន ស្របតាមលក្ខខណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

#### ១ ប្រតិភូកម្មនៅក្នុងរបៀបរបបការងាររបស់គណៈអភិបាលក្រុង

ចំពោះការធ្វើប្រតិភូកម្មនៅថ្នាក់ក្រុងនេះវិញ អភិបាលក្រុង អាចប្រគល់សិទ្ធិដល់អភិបាលរងក្រុងនៅក្នុងការចុះហត្ថលេខាលើឯកសារ លិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួន នៅក្នុងក្របខណ្ឌនៃភារកិច្ច ដែលបានបែងចែកជូនអភិបាលរងក្រុងនីមួយៗ។ ប៉ុន្តែ អភិបាលក្រុងត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមបែបបទ និងនីតិវិធី ចំពោះឯកសារ លិខិតស្នាម ដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងក្រុងទាំងនោះ និងមានសិទ្ធិដកហូតមកវិញ នូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងក្រុងណាមួយដែលប្រើប្រាស់អំណាចនេះមិនស្របច្បាប់ មិនស្របតាមបែបបទ និងនីតិវិធី។ ការប្រគល់ និងការដកហូតនូវសិទ្ធិចុះហត្ថលេខានេះត្រូវរាយការណ៍ជូនក្រុមប្រឹក្សាក្រុងរបស់ខ្លួន។

ប្រសិនបើអភិបាលក្រុងអវត្តមានអភិបាលក្រុង ត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអភិបាលរងក្រុងមួយរូបឲ្យទទួលជាអភិបាលក្រុងស្ដីទី។ ប្រសិនបើអភិបាលក្រុងអវត្តមានដោយពុំបានផ្ទេរសិទ្ធិ អភិបាលរងក្រុងដែលស្ថិតនៅលំដាប់លេខរៀងលើគេ នៃអនុក្រឹត្យតែងតាំងអភិបាលរងនៃគណៈអភិបាលក្រុងត្រូវធ្វើជាអភិបាលក្រុងស្ដីទី។ ក្នុងករណីដែលអភិបាលក្រុងស្ដីទីអវត្តមានអភិបាលរាជធានី ខេត្ត ត្រូវចេញដីកា ដើម្បីប្រគល់ភារកិច្ចដល់អភិបាលរងក្រុងមួយរូបឲ្យទទួលជាអភិបាលក្រុងស្ដីទី និងត្រូវធ្វើសេចក្ដីរាយការណ៍ជូនរដ្ឋបាលរាជធានី ខេត្តធ្វើសេចក្ដីរាយការណ៍មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលក្រុងស្ដីទីត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្តជូនអភិបាលក្រុង នៅពេលដែលអភិបាលក្រុងមានវត្តមានវិញ។ គណៈអភិបាលក្រុង ឬអភិបាលក្រុង ឬអភិបាលរងក្រុងដែលបានសម្រេច និងឬដែលបានអនុវត្តកិច្ចការណាមួយ ផ្ទុយនឹងច្បាប់លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណា ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាក្រុង ការសម្រេច ឬសកម្មភាពនោះ ពុំមានសុពលភាពឡើយ។ គណៈអភិបាលក្រុង ឬអភិបាលក្រុង ឬអភិបាលរងក្រុង ត្រូវទទួលខុសត្រូវ ចំពោះមុខច្បាប់អំពីការសម្រេច ឬសកម្មភាពទាំងនេះ។

### ២ ប្រតិភូកម្មក្នុងទំនាក់ទំនងរវាងរដ្ឋបាលក្រុងជាមួយរដ្ឋបាលឃុំ សង្កាត់

ក្រុមប្រឹក្សាសង្កាត់ក្នុងក្រុង ត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងរបស់ក្រុមប្រឹក្សាក្រុង ដីកា ឬសេចក្ដីសម្រេចនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវស្ថិតក្រោមការពិនិត្យនីត្យានុកូលភាពរបស់ក្រុមប្រឹក្សាក្រុង ។ ក្រុមប្រឹក្សាក្រុង ត្រូវធ្វើប្រតិភូកម្មដល់គណៈអភិបាលក្រុង ដើម្បីពិនិត្យនីត្យានុកូលភាពនេះ។

ក្រុមប្រឹក្សាក្រុង ត្រូវធានាធ្វើប្រតិភូកម្មឲ្យបានសមស្របនូវមុខងារ និងភារកិច្ចដល់ក្រុមប្រឹក្សាសង្កាត់ក្នុងក្រុងរបស់ខ្លួន។ ដើម្បីធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចដល់ក្រុមប្រឹក្សាសង្កាត់ក្នុងក្រុង ក្រុមប្រឹក្សាក្រុងត្រូវធ្វើការពិគ្រោះយោបល់ និងការសម្របសម្រួលឲ្យបានសមស្របជាមួយក្រុមប្រឹក្សាសង្កាត់ ដើម្បីរួមគ្នាពិចារណាអំពីភាពសមហេតុផល និងប្រសិទ្ធិភាពនៃមុខងារ និងភារកិច្ចដែលគួររក្សាទុកជាមុខងារ និងភារកិច្ចរបស់ក្រុង ស្រុក ខណ្ឌ ឬគួរធ្វើប្រតិភូកម្មទៅឲ្យក្រុមប្រឹក្សាឃុំសង្កាត់នៃក្រុងរបស់ខ្លួន។ ក្រុមប្រឹក្សាក្រុងត្រូវ ធានាផ្ដល់មធ្យោបាយសម្ភារៈ ធនធាននានារួមទាំងធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងការបណ្ដុះបណ្ដាលកសាងសមត្ថភាពដល់ក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិកក្រុមប្រឹក្សាសង្កាត់ដើម្បីអនុវត្តមុខងារ និងភារកិច្ចដែលបានធ្វើប្រតិភូកម្មពីក្រុមប្រឹក្សាក្រុង ។ ក្រុមប្រឹក្សាក្រុងត្រូវធ្វើការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់ដើម្បីធានាថា ក្រុមប្រឹក្សាសង្កាត់អនុ-

វត្តមុខងារ និងភារកិច្ចក្នុងក្របខណ្ឌនៃអំណាចដែលបានផ្ទេរប្រតិភូកម្មឲ្យលើមូលដ្ឋាននៃការគោរព រដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ហើយត្រូវធានាថា ក្រុមប្រឹក្សាសង្កាត់ បានអនុវត្តមុខងារ និងភារកិច្ចនេះ ក្នុងការឆ្លើយតបបានយ៉ាងប្រសើរបំផុតនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

ឧទាហរណ៍ ក្រុមប្រឹក្សាក្រុង បានទទួលការផ្ទេរមុខងារគ្រប់គ្រងសំរាមក្នុងក្រុង។ ក្រុមប្រឹក្សាក្រុងអាចធ្វើប្រតិភូកម្មអំណាចដល់សង្កាត់នូវមុខងារមួយចំនួនដើម្បីៈ

- ពិនិត្យតាមដានគុណភាពនៃការប្រមូលសំរាមនៅតាមផ្ទះក្នុងសង្កាត់
- ដាក់ធុងសំរាមនៅតាមទីសាធារណៈនៅក្នុងសង្កាត់ និងចាត់ចែងយកសំរាមដែលមានក្នុងធុងចេញ
- ផ្តល់អនុសាសន៍អំពីទីកន្លែងដែលត្រូវដាក់ធុងសំរាមធំនៅសង្កាត់សម្រាប់ប្រើប្រាស់

នៅពេលក្រុមប្រឹក្សាក្រុងធ្វើប្រតិភូកម្មដល់ក្រុមប្រឹក្សាសង្កាត់ក្រុមប្រឹក្សាក្រុងត្រូវផ្ទេរហិរញ្ញវត្ថុ និងបគ្គលិកដែលចាំបាច់ក៏ដូចជាការអភិវឌ្ឍន៍សមត្ថភាពជាចាំបាច់ដើម្បីអនុវត្តមុខងារ។

នៅក្នុងករណីពិនិត្យឃើញថា ដីកា ឬសេចក្តីសម្រេចណាមួយរបស់ក្រុមប្រឹក្សា សង្កាត់ មិនសមស្រប លិខិតបទដ្ឋានគតិយុត្តនានានឹងគោលការណ៍ដែលសម្រេចដោយក្រុមប្រឹក្សាក្រុង ឬការសម្រេច ឬការងារណាមួយដែលក្រុមប្រឹក្សាក្រុងបានធ្វើប្រតិភូកម្មឲ្យនោះ គណៈអភិបាលក្រុង ត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរជូនដល់ក្រុមប្រឹក្សាសង្កាត់ ដោយបញ្ជាក់ឲ្យបានច្បាស់លាស់អំពីសេចក្តីសម្រេចជាក់លាក់ និងកិច្ចការជាក់លាក់ណាមួយ ឬមួយចំនួនដែលក្រុមប្រឹក្សាសង្កាត់ធ្វើការសម្រេចដោយមិនសមស្រប ឬខុសទៅនឹងអ្វីដែលច្បាប់បានកំណត់។ ផ្អែកតាមការណែនាំនេះ ក្រុមប្រឹក្សាសង្កាត់ត្រូវកែតម្រូវសេចក្តីសម្រេច ឬសកម្មភាពរបស់ខ្លួនឲ្យបានសមស្របឡើងវិញ ក្នុងរយៈពេល ១៥ ថ្ងៃ បន្ទាប់ពីទទួលបានការណែនាំ ជាលាយលក្ខណ៍អក្សរពីគណៈអភិបាលក្រុង ។ ក្នុងករណីក្រុមប្រឹក្សា សង្កាត់ មិនអនុវត្តតាមការណែនាំខាងលើនេះ ក្រុមប្រឹក្សាក្រុង ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារាជធានីខេត្តដើម្បីសម្របសម្រួលអនុវត្តតាមនីតិវិធី។

### ខ-គណៈអភិបាលនៃអភិបាលស្រុក

ស្រុកនីមួយៗត្រូវមានគណៈអភិបាលស្រុកមួយដែលរួមមាន អភិបាលស្រុក និងអភិបាលរងស្រុកមួយចំនួនស្របតាមលក្ខខណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ក្នុងការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន គណៈអភិបាលស្រុក ត្រូវគោរពតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ការណែនាំរបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានា និងត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័ននានាស្របទៅតាមច្បាប់

និងលិខិតបទដ្ឋានគតិយុត្តនានា[១៩] ។

### ១- ប្រតិភូកម្មនៅក្នុងរបៀបរបបការងាររបស់គណៈអភិបាលស្រុក

ក្នុងការធ្វើប្រតិភូកម្មថ្នាក់ស្រុកនេះ អភិបាលស្រុក អាចប្រគល់សិទ្ធិដល់អភិបាលរងស្រុកនៅក្នុងការចុះហត្ថលេខាលើឯកសារ លិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួន នៅក្នុងក្របខណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងស្រុកនីមួយៗ ប៉ុន្តែ ត្រូវទទួលខុសត្រូវ អំពីភាពត្រឹមត្រូវតាមបែបបទ និងនីតិវិធី ចំពោះឯកសារ លិខិតស្នាម ដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងស្រុកទាំងនោះ។ អភិបាលស្រុកមានសិទ្ធិដកហូតមកវិញ នូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងស្រុកណាមួយដែលប្រើប្រាស់អំណាចនេះមិនស្របច្បាប់ មិនស្របតាមបែបបទ និងនីតិវិធី ដោយការប្រគល់ និងការដកហូតសិទ្ធិនៃការចុះហត្ថលេខានេះត្រូវជូនដំណឹងទៅក្រុមប្រឹក្សាស្រុករបស់ខ្លួន ។ លើសពីនេះក្នុងករណីអភិបាលស្រុក អវត្តមាន អភិបាលស្រុកត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអភិបាលរងស្រុកមួយរូប ឲ្យទទួលជាអភិបាលស្រុកស្ដីទី។ ប្រសិនបើអភិបាលស្រុកអវត្តមានដោយពុំបានផ្ទេរសិទ្ធិ អភិបាលរងស្រុកដែលស្ថិតនៅលំដាប់លេខរៀងលើគេ នៃអនុក្រឹត្យតែងតាំងអភិបាលរងនៃគណៈអភិបាលស្រុកត្រូវធ្វើជាអភិបាលស្រុកស្ដីទី។ ក្នុងករណីដែលអភិបាលស្រុកស្ដីទីអវត្តមាន អភិបាលខេត្ត ត្រូវចេញដីកា ដើម្បីប្រគល់ភារកិច្ចដល់អភិបាលរងស្រុកមួយរូបឲ្យទទួលជាអភិបាលស្រុកស្ដីទី និងត្រូវធ្វើសេចក្ដីរាយការណ៍ជូនរដ្ឋបាលខេត្ត ដើម្បីរដ្ឋបាលខេត្តធ្វើសេចក្ដីរាយការណ៍មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ អភិបាលស្រុកស្ដីទី ត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្តជូនអភិបាលស្រុក នៅពេលដែលអភិបាលស្រុកមានវត្តមានវិញ។ គណៈអភិបាលស្រុក ឬអភិបាលស្រុក ឬអភិបាលរងស្រុកដែលបានសម្រេច និងឬដែលបានអនុវត្តកិច្ចការណាមួយផ្ទុយនឹងច្បាប់លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណា ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាស្រុក ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាស្រុក ការសម្រេច ឬសកម្មភាពនោះពុំមានសុពលភាពឡើយ។ គណៈអភិបាលស្រុក ឬអភិបាលស្រុក ឬអភិបាលរងស្រុក ត្រូវទទួលខុសត្រូវ ចំពោះមុខច្បាប់អំពីការសម្រេច ឬសកម្មភាពទាំងនេះ។

### ២ ប្រតិភូកម្មក្នុងទំនាក់ទំនងរវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលឃុំ

ក្រុមប្រឹក្សាឃុំនៅក្នុងស្រុក ត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងរបស់ក្រុមប្រឹក្សាស្រុក

[១៩] អនុក្រឹត្យស្ដីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦អនក្រ.បក, ១៤ ធ្នូ ២០០៩,មាត្រា១៥៦

ដីកា ឬសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាឃុំ ត្រូវស្ថិតក្រោមការពិនិត្យនីត្យានុកូលភាពរបស់ក្រុមប្រឹក្សាស្រុក ។ ក្រុមប្រឹក្សាស្រុក ត្រូវធ្វើប្រតិភូកម្មដល់គណៈអភិបាលស្រុកដើម្បីពិនិត្យនីត្យានុ-កូលភាពនេះ។

ក្រុមប្រឹក្សាស្រុក ត្រូវធានាធ្វើប្រតិភូកម្មឲ្យបានសមស្របនូវមុខងារ និងភារកិច្ចដល់ក្រុមប្រឹក្សាឃុំក្នុងក្រុងរបស់ខ្លួន។ ដើម្បីធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចដល់ក្រុមប្រឹក្សាឃុំក្នុងស្រុក ក្រុមប្រឹក្សាស្រុកត្រូវធ្វើការពិគ្រោះយោបល់ និងការសម្របសម្រួលឲ្យបានសមស្របជាមួយក្រុមប្រឹក្សាឃុំ ដើម្បីរួមគ្នាពិចារណាអំពីភាពសមហេតុផល និងប្រសិទ្ធិភាពនៃមុខងារ និងភារកិច្ច ដែលគួររក្សាទុកជាមុខងារ និងភារកិច្ចរបស់ស្រុក ឬគួរធ្វើប្រតិភូកម្មទៅឲ្យក្រុមប្រឹក្សាឃុំ នៃស្រុករបស់ខ្លួន។ ក្រុមប្រឹក្សាស្រុកត្រូវ ធានាផ្តល់មធ្យោបាយ សម្ភារៈ ធនធាននានារួមទាំងធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងការបណ្តុះបណ្តាលកសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ និងបុគ្គលិកក្រុមប្រឹក្សាឃុំដើម្បីអនុវត្តមុខងារ និងភារកិច្ចដែលបានធ្វើប្រតិភូកម្មពីក្រុមប្រឹក្សាឃុំ ។ ក្រុមប្រឹក្សាស្រុកត្រូវធ្វើការគាំទ្រដល់ក្រុមប្រឹក្សាឃុំដើម្បីធានាថា ក្រុមប្រឹក្សាឃុំអនុវត្តមុខងារ និងភារកិច្ចក្នុងក្របខណ្ឌនៃអំណាចដែលបានធ្វើប្រតិភូកម្មឲ្យលើមូលដ្ឋាននៃការគោរពរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ហើយត្រូវធានាថា ក្រុមប្រឹក្សាឃុំ បានអនុវត្តមុខងារ និងភារកិច្ចនេះ ក្នុងការឆ្លើយតបបានយ៉ាងប្រសើរបំផុតនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

នៅក្នុងករណីពិនិត្យឃើញថា ដីកា ឬសេចក្តីសម្រេចណាមួយរបស់ក្រុមប្រឹក្សាឃុំ មិនសមស្រប លិខិតបទដ្ឋានគតិយុត្តនានានឹងគោលការណ៍ដែលសម្រេចដោយក្រុមប្រឹក្សាស្រុក ឬការសម្រេច ឬការងារណាមួយដែលក្រុមប្រឹក្សាស្រុកបានធ្វើប្រតិភូកម្មឲ្យនោះ គណៈអភិបាលស្រុកត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរជូនដល់ក្រុមប្រឹក្សាឃុំ ដោយបញ្ជាក់ឲ្យបានច្បាស់លាស់អំពីសេចក្តីសម្រេចជាក់លាក់ និងកិច្ចការជាក់លាក់ណាមួយ ឬមួយចំនួនដែលក្រុមប្រឹក្សាឃុំធ្វើការសម្រេចដោយមិនសមស្រប ឬខុសទៅនឹងអ្វីដែលច្បាប់បានកំណត់។ ផ្អែកតាមការណែនាំនេះក្រុមប្រឹក្សាឃុំត្រូវកែតម្រូវសេចក្តីសម្រេច ឬសកម្មភាពរបស់ខ្លួនឲ្យបានសមស្របឡើងវិញ ក្នុងរយៈពេល ១៥ ថ្ងៃបន្ទាប់ពីទទួលបានការណែនាំ ជាលាយលក្ខណ៍អក្សរពីគណៈអភិបាលស្រុក ។ ក្នុងករណីក្រុមប្រឹក្សាឃុំ មិនអនុវត្តតាមការណែនាំខាងលើនេះ ក្រុមប្រឹក្សាស្រុក ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារាជធានីខេត្តដើម្បីសម្របសម្រួលអនុវត្តតាមនីតិវិធី។

### គ-អភិបាលនៃគណៈអភិបាលខណ្ឌ

ខណ្ឌនីមួយៗត្រូវមានគណៈអភិបាលខណ្ឌមួយដែលរួមមាន អភិបាលខណ្ឌនិងអភិបាលរង

ខណ្ឌមួយចំនួន ស្របតាមលក្ខខណ្ឌ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ផ្អែកតាមការធ្វើប្រតិភូកម្មមុខងារ ភារកិច្ចពីក្រុមប្រឹក្សារាជធានី គណៈអភិបាលខណ្ឌត្រូវធ្វើការសិក្សាស្រាវជ្រាវ ផ្តល់យោបល់ជូនក្រុមប្រឹក្សាខណ្ឌ ដើម្បីធ្វើការពិភាក្សា និងសម្រេចផ្អែកតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងបែបបទនីតិវិធីនៃមុខងារ ភារកិច្ចដែលបានទទួលប្រតិភូកម្មនោះ[២០]។

## ១ ប្រតិភូកម្មនៅក្នុងរបៀបរបបការងាររបស់គណៈអភិបាលខណ្ឌ

នៅក្នុងរបៀបរបបការងាររបស់អភិបាលខណ្ឌ អភិបាលខណ្ឌ ត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាល សម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ដើម្បីអនុវត្តសេចក្តីសម្រេចនៃក្រុមប្រឹក្សាខណ្ឌរបស់ខ្លួន លើកលែងតែលិខិតបទដ្ឋានដែលតម្រូវឲ្យប្រធានក្រុមប្រឹក្សាខណ្ឌ ចុះហត្ថលេខា នៅក្នុងនាមក្រុមប្រឹក្សាខណ្ឌរបស់ខ្លួន។ អភិបាលខណ្ឌ អាចប្រគល់សិទ្ធិដល់អភិបាលរងខណ្ឌនៅក្នុងការចុះហត្ថលេខាលើឯកសារ លិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួន នៅក្នុងក្របខណ្ឌនៃភារកិច្ច ដែលបានបែងចែកជូនអភិបាលរងខណ្ឌនីមួយៗ។ អភិបាលខណ្ឌត្រូវទទួលខុសត្រូវ អំពីភាពត្រឹមត្រូវតាមបែបបទ និងនីតិវិធី ចំពោះឯកសារ លិខិតស្នាម ដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងខណ្ឌទាំងនោះ។ អភិបាលខណ្ឌមានសិទ្ធិដកហូតមកវិញ នូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងខណ្ឌណាមួយដែលប្រើប្រាស់អំណាចនេះមិនស្របច្បាប់ មិនស្របតាមបែបបទ និងនីតិវិធី។ លើសពីនេះក្នុងករណីអភិបាលខណ្ឌ អវត្តមាន អភិបាលខណឌត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ ជូនអភិបាលរងខណ្ឌមួយរូប ឲ្យទទួលជាអភិបាលខណ្ឌស្តីទី។ ប្រសិនបើអភិបាលខណ្ឌអវត្តមានដោយពុំបានផ្ទេរសិទ្ធិ អភិបាលរងខណ្ឌដែលស្ថិតនៅលំដាប់លេខរៀងលើគេ នៃអនុក្រឹត្យតែងតាំងអភិបាលរងនៃគណៈអភិបាលខណ្ឌ ត្រូវធ្វើជាអភិបាលខណ្ឌស្តីទី។ ក្នុងករណីដែលអភិបាលខណ្ឌស្តីទីអវត្តមាន អភិបាលរាជធានី ត្រូវចេញដីកា ដើម្បីប្រគល់ភារកិច្ចដល់អភិបាលរងខណ្ឌមួយរូបឲ្យទទួលជាអភិបាលខណ្ឌស្តីទី និងត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋបាលរាជធានី ខេត្ត ធ្វើសេចក្តីរាយការណ៍មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខណ្ឌស្តីទីត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្តជូនអភិបាលខណ្ឌ នៅពេលដែលអភិបាលខណ្ឌមានវត្តមានវិញ។ គណៈអភិបាលខណ្ឌ ឬអភិបាលខណ្ឌ ឬអភិបាលរងខណ្ឌដែលបានសម្រេច និងឬដែលបានអនុវត្តកិច្ចការណា

---

[២០] អនុក្រឹត្យស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ, លេខ២១៥អនក្រ.បក, ១៤ ធ្នូ ២០០៩,មាត្រា៨៧

មួយ ផ្ទុយនឹងច្បាប់លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណា ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខណ្ឌ ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាក្រុង ការសម្រេច ឬសកម្មភាពនោះពុំមានសុពលភាពឡើយ។ គណៈអភិបាលខណ្ឌ ឬអភិបាលខណ្ឌ ឬអភិបាលរងខណ្ឌ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីការសម្រេច ឬសកម្មភាពទាំងនោះ។

**២ ប្រតិភូកម្មក្នុងទំនាក់ទំនងរវាងរដ្ឋបាលខណ្ឌជាមួយរដ្ឋបាលសង្កាត់**

ក្រុមប្រឹក្សាខណ្ឌត្រូវគាំទ្រសមត្ថភាពចាំបាច់ដល់ក្រុមប្រឹក្សាសង្កាត់ ដើម្បីឲ្យក្រុមប្រឹក្សាសង្កាត់ក្នុងខណ្ឌ មានសមត្ថភាពទទួលបាននូវមុខងារ និងភារកិច្ចដែលត្រូវធ្វើប្រតិភូកម្មកាន់តែច្រើនថែមទៀត ពីក្រុមប្រឹក្សារាជធានីសំដៅឆ្លើយតបតម្រូវការប្រជាពលរដ្ឋ[២១] ។ ដូចនេះក្រុមប្រឹក្សាខណ្ឌត្រូវធ្វើការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់ដើម្បីធានាថា ក្រុមប្រឹក្សាសង្កាត់អនុវត្តមុខងារ និងភារកិច្ចក្នុងក្របខណ្ឌនៃអំណាចដែលបានធ្វើប្រតិភូកម្មឲ្យលើមូលដ្ឋាននៃការគោរពរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ហើយត្រូវធានាថា ក្រុមប្រឹក្សាសង្កាត់ បានអនុវត្តមុខងារ និងភារកិច្ចនេះ ក្នុងការឆ្លើយតបបានយ៉ាងប្រសើរបំផុតនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

## កថាខណ្ឌ៣ រដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ គឺជាតួអង្គមួយដ៏សំខាន់ក្នុងការអនុវត្តនូវកាគ្រប់គ្រងតាមប្រព័ន្ធវិមជ្ឈការក៏ដូចជាវិសហមជ្ឈការ។ រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញ និងគាំពារអភិបាលកិច្ចល្អដោយចាត់ចែងប្រើប្រាស់ធនធាននានាប្រកបដោយចីរភាពសម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ[២២]។

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរយ៉ាង។ទីមួយមានតួនាទីបម្រើកិច្ចការមូលដ្ឋានសម្រាប់បម្រើផលប្រយោជន៍ឃុំ សង្កាត់ និងប្រជាពលរដ្ឋខ្លួន។ ទីពីមានតួនាទីភ្នាក់ងារតំណាងរដ្ឋក្រោមការចាត់តាំង ឬប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ[23]។

---

[២១] អនុក្រឹត្យស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ, លេខ២១៥អនក្រ.បក, ១៨ ធ្នូ ២០០៩,មាត្រា១១៧

[២២] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,លេខនស/រកម/០៣០១/០៥, ១៩ មីនា ២០០១,មាត្រា៤១

[២៣] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,លេខនស/រកម/០៣០១/០៥, ១៩ មីនា ២០០១,មាត្រា៤២

**❖តួនាទីបម្រើកិច្ចការមូលដ្ឋាន**

ក្នុងនាមជាអ្នកបម្រើកិច្ចការមូលដ្ឋាន ក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីដូចជា៖

- ធានារក្សាសន្តិសុខសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាចាំបាច់ និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការល្អ
- លើកទឹកចិត្តឱ្យមានការបង្កើនជាសុកភាព និងសុខុមាលភាពប្រជាពលរដ្ឋ
- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌បេតិកភណ្ឌជាតិ
- សម្រួលទស្សនៈ ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក
- បំពេញកិច្ចការទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ[២៤]។

**❖តួនាទីជាភ្នាក់ងាររបស់រដ្ឋាភិបាល**

ក្នុងតួនាទីជាអ្នកតំណាងរដ្ឋ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ ។ ក្នុងករណីនេះអាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាព ផ្គត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកា សម្រាប់អនុ វត្ត។ ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ ប៉ុន្តែក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើប្រតិភូកម្មអំណាចទៅឲ្យមេឃុំ ចៅសង្កាត់ជាអ្នកអនុវត្តផ្ទាល់បាន[២៥] តែមេឃុំ ចៅសង្កាត់ដែលត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើប្រតិភូកម្មអំណាចឲ្យពុំអាចផ្ទេរអំណាចនេះបន្តទៅឲ្យបុគ្គលដទៃទៀតបានឡើយ។ បំពេញតួនាទីក្នុងនាមរដ្ឋ តួនាទីទាំងនោះរួមមាន៖

- ការចុះបញ្ជីអត្រានុកូលដ្ឋានៈ មានដូចជាការចុះសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រមរណភាពជាដើម
- ការចុះឈ្មោះអ្នកបោះឆ្នោត ដែលត្រូវបានធ្វើប្រតិភូកម្មដោយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ការចុះបញ្ជីបញ្ជាក់អំពីកម្មសិទ្ធិដីធ្លី ដែលបានប្រគល់អំណាចអំពីក្រសួងរៀបចំដែនដីនគររូប-នីយកម្ម និងសំណង់។

---

[២៤] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,លេខនស/រកម/០៣០១/០៥, ១៩ មីនា ២០០១,មាត្រា៤៣

[២៥] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,លេខនស/រកម/០៣០១/០៥, ១៩ មីនា ២០០១,មាត្រា៥១

ក្នុងការអនុវត្តជាក់ស្តែងសង្កេតឃើញមានការធ្វើប្រតិភូកម្មមួយចំនួនពីថ្នាក់ជាតិ ទៅថ្នាក់រដ្ឋបាលមូលដ្ឋាននេះដែរដូចជា៖

អនុក្រឹត្យលេខ២២ អនក្រ ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០០២ស្តីអំពី វិមជ្ឈការ អំណាច តួនាទី និងភារកិច្ចឲ្យទៅក្រុមប្រឹក្សាឃុំ សង្កាត់ បានកំណត់ថា រាល់ក្រសួងស្ថាប័នដែលមានបំណងធ្វើប្រតិភូកម្មអំណាច ឬការទទួលខុសត្រូវ ឬធ្វើកិច្ចព្រមព្រៀងណាមួយទៅក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវផ្ទេរធនធាន និងសមត្ថភាពជាចាំបាច់ដើម្បីធានាឲ្យក្រុមប្រឹក្សាឃុំ សង្កាត់អនុវត្តបាននូវអំណាច ឬការទទួលខុសត្រូវ ឬកិច្ចព្រមព្រៀងដែលបានធ្វើប្រតិភូកម្មនោះ តាមរយៈនៃការធ្វើប្រតិភូកម្មនេះឃុំ សង្កាត់មានអំណាចសម្រេចដោយផ្ទាល់ទៅលើចំណូល និងចំណាយរបស់ខ្លួនដែលច្បាប់បានកំណត់ឲ្យបានសេចក្តីថា នៅក្នុងឃុំ សង្កាត់នីមួយៗត្រូវមានធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខ្លួនផ្ទាល់សម្រាប់ដំណើរការកិច្ចការឃុំ សង្កាត់។ ការធ្វើប្រតិភូកម្មអំណាចហិរញ្ញវត្ថុនេះគឺជានយោបាយថ្មីថ្មោងសម្រាប់កម្ពុជា ដែលវាមានលក្ខណៈស្មុគស្មាញទាំងការគ្រប់គ្រងធនធាន ទាំងការរៀបចំ និងការអនុម័តថវិកាឃុំ សង្កាត់ដែលធ្វើឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានចែងថា ឃុំ សង្កាត់ត្រូវមានធនធានហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន[២៦]។

យោងតាមមាត្រា២នៃអនុក្រឹត្យស្តីពីមូលនិធិឃុំ សង្កាត់ គោលបំណងនៃការបង្កើតឱ្យមានការប្រតិភូកម្មអំណាចហិរញ្ញវត្ថុនេះឡើងដើម្បីឱ្យ៖

- ឃុំ សង្កាត់អាចរ៉ាប់រងការទទួលខុសត្រូវជាទូទៅលើការងាររដ្ឋបាលមូលដ្ឋាន និងជំរុញកិច្ចអភិវឌ្ឍន៍នៅមូលដ្ឋានស្របទៅនឹងមាត្រា៤២ ៤៣ និងមាត្រា៤៤នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។
- កាត់បន្ថយភាពខុសគ្នាអំពីសក្តានុពលក្នុងការប្រមូលចំណូលផ្ទាល់រវាងឃុំ សង្កាត់នានាដោយស្ថានភាពអាចនឹងផ្សេងគ្នា អាស្រ័យលើលក្ខខណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ច សង្គម និងប្រជាសាស្ត្រ។
- ជួយជំរុញលើកទឹកចិត្តដល់ការកសាងសមត្ថភាព សម្រាប់ការងារអភិបាលកិច្ចល្អក្នុងក្រុមប្រឹក្សាឃុំ សង្កាត់។

[២៦] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,លេខនស/រកម/០៣០១/០៥, ១៩ មីនា ២០០១,មាត្រា៧៣

# សេចក្តីសន្និដ្ឋាន

ក្រោយពីធ្វើការបកស្រាយជាបន្តបន្ទាប់រួចមក បានសបញ្ជាក់ឱ្យឃើញថា ប្រតិភូកម្មពិតជាមានតម្លៃណាស់នៅក្នុងវិស័យរដ្ឋបាលសាធារណៈ ព្រោះថាការគ្រប់គ្រងរដ្ឋបាលបានល្អលុះត្រាតែមានប្រតិភូកម្ម បើពុំដូច្នោះទេសេវាសាធារណៈនឹងត្រូវប្រមូលផ្តុំនៅរដ្ឋបាលកណ្តាល(ជាតិ) ដែលនាំឱ្យមានភាពរាំងស្ទះដល់ដំណើរការការងារ ជាហេតុបង្កឱ្យមានឧបសគ្គដល់ការអភិវឌ្ឍន៍ប្រទេសជាតិ។ ម្យ៉ាងទៀតបើគ្មានប្រតិភូកម្មគោលការណ៍តម្លាភាពនៃរដ្ឋបាលសាធារណៈពិតជាមិនអាចធ្វើទៅបានគ្រប់ជ្រុងជ្រោយទេព្រោះ ប្រតិភូកម្មនេះបានជួយកាត់បន្ថយបានយ៉ាងច្រើននូវការិយាធិបតេយ្យដែលតឹងតែងបំផុត និងមានលក្ខណៈសាំញ៉ាំនៅក្នុងនីតិរដ្ឋបាល។ ការធ្វើប្រតិភូកម្មនេះជាទម្រង់មួយនៃការគ្រប់គ្រងតាមបែបវិសមជ្ឈការ មានន័យថា រដ្ឋាភិបាលបានធ្វើប្រតិភូកម្មមុខងារសិទ្ធិអំណាច ធនធានឱ្យទៅរដ្ឋបាលថ្នាក់មូលដ្ឋាន ឬអង្គភាពក្រោមបង្គាប់ ឬក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តសកម្មភាពរបស់ខ្លួនកក្នុងនាមរដ្ឋាភិបាល ឬថ្នាក់ជាតិ។ ប្រតិភូកម្មនេះធ្វើឡើងតាមរូបភាពពីរបែប ពោលគឺប្រតិភូកម្មអំណាច និងប្រតិភូកម្មហត្ថលេខា។

ទន្ទឹមនឹងនោះដែរ ថ្វីត្បិតតែនៅក្នុងទ្រឹស្តី និងលិខិតបទដ្ឋានដែលបានចែងមកមានរួចហើយក៏ដោយ តែនៅក្នុងការអនុវត្តជាក់ស្តែងនៅតែមានលេចចេញនូវភាពអសកម្មមួយចំនួន ដែលចំណុចអសកម្មនោះស្ថិតនៅត្រង់ថា អាជ្ញាធរ ឬបុគ្គលដែលទទួលប្រតិភូកម្មមិនហ៊ានសម្រេចចិត្តឲ្យបានច្បាស់លាស់ក្នុងការបំពេញមុខងារ ឬភារកិច្ចដែលខ្លួនបានទទួលនោះឡើយ ព្រោះពួកគេមិនបានយល់ច្បាស់ពីសមត្ថកិច្ចដែលពួកគេទទួលបានពីការធ្វើ ប្រតិភូកម្ម។ ដោយសារហេតុនេះហើយបានជាបញ្ហាមួយចំនួននៅថ្នាក់មូលដ្ឋាន ត្រូវជាប់គាំងដោយពួកគេមិនហ៊ានសម្រេចហើយរង់ចាំការផ្តល់យោបល់ពីថ្នាក់កណ្តាល។ លើសពីនេះពេលខ្លះការអនុវត្តរបស់ពួកគេធ្វើឡើងហួសពីដែនសមត្ថកិច្ចដែលអំណាចកណ្តាលបានប្រតិភូកម្មទៅឲ្យ។

ជាមួយគ្នានេះដែរ ក្រៅពីក្នុងវិស័យរដ្ឋបាល គេក៏ប្រទះឃើញ ប្រតិភូកម្មនៅក្នុងវិស័យមួយចំនួនផ្សេងទៀតដូចជា ខាងនីតិរដ្ឋធម្មនុញ្ញ និងខាងវិស័យឯកជនជាដើម សបញ្ជាក់ឲ្យឃើញថាប្រតិភូកម្មពិតជាចាំបាច់ក្នុងបរិបទនៃការគ្រប់គ្រងនាសម័យកាលនេះ។

# អនុសាសន៍

ទម្លាប់នៃប្រតិភូកម្មមានញឹកញាប់ណាស់នៅក្នុងរដ្ឋបាល មិនថា រដ្ឋបាលបរទេស ឬកម្ពុជាទេ ដើម្បីសម្រួល និងសម្រាលបន្ទុកការងាររបស់អាជ្ញាធរមានសមត្ថកិច្ច។ ដូច្នេះក្នុងគោលបំណងបញ្ចៀសការភាន់ច្រឡំ ការបាត់បង់សណ្តាប់ធ្នាប់ ឬសង្គតិភាពនៃរដ្ឋបាល គួរមានអត្ថបទចែងពីរបបប្រតិភូកម្មមួយដែលក្នុងនោះៈ

- អាជ្ញាធរថ្នាក់ជាតិ ៖ ត្រូវកំណត់ឲ្យបានជាក់លាក់ និងច្បាស់លាស់នូវប្រភេទនៃប្រតិភូកម្មរបស់អាជ្ញាធរថ្នាក់ជាតិ មានន័យថា ត្រូវកំណត់ថា ប្រតិភូកម្មនោះជាប្រតិភូកម្មហត្ថលេខា ឬជាប្រតិភូកម្មសមត្ថកិច្ច ហើយអាជ្ញាធរ ឬបុគ្គលដែលទទួលមានតួនាទី សមត្ថិច្ច ព្រមទាំងការទទួលខុសត្រូវក្នុងកម្រិតណា និងត្រូវមានការផ្សព្វផ្សាយ ឲ្យបានទូលំទូលាយដល់មូលដ្ឋាន ដើម្បីឲ្យប្រជាពលរដ្ឋបានដឹងពីទំហំ ឬដែនសមត្ថកិច្ចរបស់អាជ្ញាធរ ឬបុគ្គលដែលទទួលបានប្រតិភូកម្ម។
- អាជ្ញាធរថ្នាក់ក្រោមជាតិៈ បុគ្គល ឬអាជ្ញាធរដែលទតួលប្រតិភូកម្មត្រូវមានសមត្ថភាព និងឯកពជ្យភាពគ្រប់គ្រាន់ក្នុងការបំពេញតួនាទី ឬភារកិច្ចដែលពួកគេបានទទួលតាមរយៈការធ្វើប្រតិភូកម្ម។
- វិវាទៈក្នុងករណីមានវិវាទក្នុងដំណើរការប្រព្រឹត្តទៅនៃប្រតិភូកម្ម មាននីតិវិធីក្នុងការដោះស្រាយយ៉ាងដូចម្តេច ហើយជាសមត្ថកិច្ចរបស់ស្ថាប័នណា ចៀសវាងការឆ្លើយដាក់បន្ទុកគ្នាទៅវិញទៅមកក្នុងករណីមានភាពអសកម្ម ឬកំហុសណាមួយកើតឡើង។

សរុបមកដើម្បីជំរុញឲ្យការប្រព្រឹត្តទៅនៃការធ្វើប្រតិភូកម្មដំណើរការទៅបានរលូន គួរមានអត្ថបទមួយចែងឲ្យបានច្បាស់លាស់ពីការធ្វើប្រតិភូកម្ម ផ្លាស់ប្តូរនូវទម្លាប់អសកម្មមួយចំនួនចោល ជាពិសេសត្រូវកំណត់ឲ្យបានច្បាស់ពីយុត្តិសាស្ត្រសម្រាប់ដោះស្រាយ ក្នុងករណីវិវាទកើតមានឡើង។

ម្យ៉ាងវិញទៀតសូមសំណូមពរដល់និស្សិត មន្ត្រីរាជការ និងប្រជាពលរដ្ឋ គួរគប្បីស្វែងយល់ឲ្យបានច្បាស់អំពីបញ្ហានេះ និងត្រូវរួមរួមគ្នាជាធ្លុងមួយ ពួតដៃគ្នា សហការគ្នា ដើម្បីចូលរួមចំណែកនាំនាវាកម្ពុជាទៅរកត្រើយមួយដ៏សុខសាន្តពោលគឺជានីតិរដ្ឋដ៏ពិតប្រាកដ និងមានកិត្តិស័ព្ទ និងកេរ្តិ៍ឈ្មោះល្បីរន្ទឺដូចកាលពីសម័យបុរាណកាល។

# ឯកសារយោង

## I. ឯកសារច្បាប់ជាតិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,លេខនស/រកម/០៣០១/០៥, ១៩ មីនា ២០០១
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ២៦ ឧសភា ២០០៨
- អនុក្រឹត្យស្តីពីមូលនិធិឃុំ សង្កាត់, លេខ១៦អនក្រ.បក, ២៥ កុម្ភៈ ២០០២
- អនុក្រឹត្យស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅអោយក្រុមប្រឹក្សាឃុំសង្កាត់, លេខ២២អនក្រ.បក ២៥ មីនា ២០០២
- អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់,លេខ២៦អនក្រ.បក,១២ មេសា ២០០២
- អនុក្រឹត្យស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជ-ធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ, លេខ២១៥អនក្រ.បក, ១៤ ធ្នូ ២០០៩
- អនុក្រឹត្យស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦អនក្រ.បក, ១៤ ធ្នូ ២០០៩
- អនុក្រឹត្យស្តីពី សមត្ថកិច្ចខេត្ត ក្រុង, លេខ២៩ អនក្រ.បក, ១២ មេសា ១៩៩៩
- សេចក្តីសម្រេចស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល, លេខ០២សសរ, ១២ មករា ២០០៧
- សេចក្តីសម្រេចស្តីពីការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល,លេខ២៨សសរ, ២៥ កញ្ញា ២០១៣
- ប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ , លេខ១៨៨៤ប្រក,១៨ មេសា ២០០២
- ប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្នុងការផ្ទៀងផ្ទាត់លក្ខខណ្ឌនានានៃសំណើសុំផ្ទេរមូលនិធិក្រុងស្រុក, លេខ២៤០៩ប្រក,០៩ កក្កដា ២០១៣
- ប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាល ក្នុងដំណើរការកិច្ចប្រជុំលើកទីមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់, លេខ៤៤៦ប្រក, ១០ មេសា ២០០៧

- ប្រកាសស្តីពីការដាក់ឲ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, លេខ១៩១១ សហវប្រក,៣១ ធ្នូ ២០១៤
- ប្រកាសស្តីពី ការបែងចែកភារកិច្ចរបស់អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ៦២២ សហវប្រក,៣១ ឧសភា ២០១៦

## II. ឯកសារជាសៀវភៅទ្រឹស្តី

- សាយ បូរី. ២០០៦. *នីតិរដ្ឋបាលទូទៅ.* ភ្នំពេញ៖ បណ្ណាគារអង្គរ។
- ឡឿក ពិដោរ. ២០០៧. *នីតិរដ្ឋបាល.* ភ្នំពេញ៖ បណ្ណាគារអង្គរ។
- ហៀង សាង. ២០១២. *ការគ្រប់គ្រងរដ្ឋបាលដែនដី.* កម្ពុជា។
- ឯកសារសម្រាប់ការយល់ដឹង និងបណ្តុះបណ្តាលអំពីច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្តក្រុង ស្រុក ខណ្ឌ។
- កៅ មុយថង.២០១០. *ការគ្រប់គ្រងរដ្ឋបាលដែនដីនៅកម្ពុជា.* ភ្នំពេញ៖ បណ្ណាគារអង្គរ។
- កៅ មុយថង. ២០០៦. *រដ្ឋធម្មនុញ្ញកម្ពុជា.* ភ្នំពេញ៖ បណ្ណាគារអង្គរ។

## III. គេហទំព័រ

- http://www.yourarticlelibrary.com/public-administration/delegation-in-public-administration-definition-and-hindrances/63433/
- http://www.managementstudyguide.com/delegation_of_authority.htm

# មាតិកាឧបសម្ព័ន្ធ

- ព្រះរាជសាររបស់ព្រះមហាក្សត្រ
- អនុក្រឹត្យលេខ៨៩៧ អនក្រ.បក របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ ចុះថ្ងៃទី០៦ ខែ វិច្ឆិកា ឆ្នាំ២០១៣
- សេចក្តីសម្រេចលេខ ២៨សសរ ស្តីពី ការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០១៣
- លិខិតសិទ្ធិប្រទានលេខ ៥៥សប្រទ នៃរាជរដ្ឋាភិបាល ចុះក្នុងរាជកិច្ច សប្តាហ៍ទី១ ថ្ងៃទី០៤ កុម្ភៈ ឆ្នាំ២០០៩
- សេចក្តីសម្រេចលេខ ០២សសរ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី១២ ខែ មករា ឆ្នាំ ២០០៧
- ប្រកាសលេខ ២៨០៩ប្រ.ក របស់ក្រសួងមហាផ្ទៃ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្តក្នុងការផ្ទៀងផ្ទាត់លក្ខខណ្ឌនានានៃសំណើសុំផ្ទេរមូលនិធិក្រុង ស្រុក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣
- ប្រកាសលេខ ៦២២ សហវ.ប្រក ស្តីពីការបែងចែកភារកិច្ចរបស់អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ ២០១៦
- ប្រកាសលេខ ១៥៣/១៥ ក.អ.ជ.ប្រក របស់ក្រសួងអភិវឌ្ឍជនបទ ស្តីពីការធ្វើប្រតិភូកម្មមុខងារផ្តល់សេវាអនាម័យជនបទជូនរដ្ឋបាលស្រុកគោលដៅក្នុងខេត្តកំពង់ស្ពឺ និងខេត្តត្បូងឃ្មុំ ចុះថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ ២០១៥
- ប្រកាសលេខ ១១៣ ប្រក របស់ក្រសួងទេសចរណ៍ ស្តីពីការធ្វើប្រតិភូកម្ម នៃការងារទេសចរណ៍ជូនដល់ខណ្ឌគោលដៅ នៃសាលារាជធានីភ្នំពេញ
- ប្រកាសលេខ ១៩៩ ប្រក.សក របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ស្តីពីការធ្វើប្រតិភូកម្មអំណាចរដ្ឋបាលកណ្តាលពីក្រសួងសាធារណការ និងដឹកជញ្ជូនជូនដល់ក្រុងកំពង់ចាម នៃខេត្តកំពង់ចាម ចុះថ្ងៃទី០៤ ខែ មិថុនា ឆ្នាំ២០១៤
- ប្រកាសលេខ ៤២១ ប្រក.កសក របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការធ្វើប្រតិភូកម្មមុខងារនៃវិស័យកសិកម្មជូនការិយាល័យច្រកចេញចូលតែមួយនៅក្រុង ស្រុកគោលដៅ ចុះថ្ងៃទី០៤ ខែ សីហា ឆ្នាំ ២០១១

- ប្រកាសលេខ ៤២៥ ស.ន.ប របស់ក្រសួងសុខាភិបាល ស្តីពីការធ្វើប្រតិភូកម្មមុខងារនៃវិស័យសុខាភិបាលជូនការិយាល័យច្រកចេញចូលតែមួយនៅស្រុកបវេល ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ ២០១៣
- ប្រកាសលេខ ១៦៥ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីការធ្វើប្រតិភូកម្មការងារពាណិជ្ជកម្មជូនដល់ ក្រុង ស្រុក ខណ្ឌគោលដៅ ចុះថ្ងៃទី១០ ខែ វិច្ឆិកា ឆ្នាំ២០១០
- លិខិតផ្ទេរសិទ្ធិលេខ ៦៤០ សជណ របស់សាលាខេត្តសៀមរាប ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥
- លិខិតផ្ទេរសិទ្ធិលេខ០០១/១៦ សជណ របស់រដ្ឋបាលខេត្តសៀមរាប ចុះថ្ងៃទី១០ ខែ មិថុនា ឆ្នាំ ២០១៦